ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៤ លេខ២ | មេសា - មិថុនា ឆ្នាំ២០១០ | តម្លៃ ១.៥០០រ

20
ខួបលើកទី
CDRI 1990-2010

## "ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ-អាទិភាពខាងគោលនយោបាយ និង សកម្មភាព ដើម្បីកំណើន និងការអភិវឌ្ឍមានចីរភាព" ៖ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី ៤ [១]

### សេចក្ដីផ្ដើម

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា លើកទី៤ លើប្រធានបទ "ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ" បានប្រារព្ធឡើងនៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី ១៧ មីនា ២០១០ ក្រោមកិច្ចសហការជាដៃគូរវាង វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង ធនាគារ ANZ Royal ។ ជាថ្មីម្ដងទៀត សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ដល់កិត្តិយសដ៏ខ្ពង់ខ្ពស់តាមការអញ្ជើញចូលរួម ជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះក្នុងពិធីបើកសន្និសីទ ជូនដល់ភ្ញៀវកិត្តិយសជាង ៣៥០នាក់ ជាថ្នាក់ដឹកនាំមកពីជួររដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ។



សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងទស្សនាផ្ទាំងរូបភាពស្ដីពីប្រវត្តិរបស់ វិទ្យាស្ថាន CDRI ក្នុងរយៈពេល ២០ឆ្នាំ ដែលដាក់តាំងបង្ហាញនៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០

ក្នុងពេលថ្លែងសុន្ទរកថា សម្ដេចនាយករដ្ឋមន្ត្រីបានបញ្ជាក់ថា "សន្និសីទរបស់យើងឆ្នាំនេះមានសារៈសំខាន់ណាស់ ដោយសារឆ្នាំនេះ ជាខួបលើកទី ២០ នៃការបង្កើតវិទ្យាស្ថាន CDRI ដែលជាអ្នករៀបចំសន្និសីទនៅថ្ងៃនេះ និងជាស្ថាប័នស្រាវជ្រាវកម្ពុជា ឯករាជ្យឈានមុខខាងគោលនយោបាយអភិវឌ្ឍន៍ ។ វិទ្យាស្ថាន CDRI បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្ដល់អនុសាសន៍ខាងគោលនយោបាយ ដែលផ្អែកលើការស្រាវជ្រាវ និងភស្ដុតាងច្បាស់លាស់ជូនរាជរដ្ឋាភិបាល និងភាគីផ្សេងទៀតដែលពាក់ព័ន្ធក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ។ ...ប្រទេសកម្ពុជាបានរីកលូតលាស់ អភិវឌ្ឍ និងផ្លាស់ប្ដូរយ៉ាងច្រើនក្នុង ២០ឆ្នាំកន្លងមកនេះ ហើយវិទ្យាស្ថាន CDRI ក៏បានរីកលូតលាស់ អភិវឌ្ឍ និងផ្លាស់ប្ដូរទៅមុខ ដូចគ្នា ប៉ុន្តែបានអនុវត្តអាណត្តិរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ពោលគឺ ធ្វើការស្រាវជ្រាវខាងគោលនយោបាយប្រកបដោយឯករាជ្យ និងគុណភាព ធ្វើការបណ្ដុះបណ្ដាល និងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងសមត្ថភាពផ្សេងៗទៀតរបស់ប្រជាជនកម្ពុជា និងចូលរួមចំណែកផ្នែកបញ្ញាញាណយ៉ាងធំធេងដល់ប្រទេសជាតិ" ។

សន្និសីទនេះ ផ្ដោតលើកត្តាសំខាន់ៗ ដែលអាចជួយឲ្យកម្ពុជាសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ និងមានចីរភាព ព្រមទាំងការកាត់បន្ថយភាពក្រីក្រ ទាំងក្នុងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្នុងវិស័យសំខាន់ៗ ដូចជា កសិកម្ម អភិវឌ្ឍន៍ជនបទ ឧស្សាហកម្មទើបផុសឡើង ហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងទេសចរណ៍ ។ សន្និសីទនេះបានរកឃើញថា សំរាប់កម្ពុជា កំណើនសេដ្ឋកិច្ចក្នុងកំរិតខ្ពស់ប្រកបដោយចីរភាព ត្រូវផ្អែកលើបរិយាកាស

តទៅទំព័រ ២៣

## មាតិកា

ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ
សូចនាករ ការរំពឹងទុក និងអាទិភាព ........................ ២
ជំរុញការនាំចេញមាសសរបស់កម្ពុជា ........................ ៦
ការពង្រឹងវិស័យសំខាន់ៗដើម្បីសំរេចបានកំណើន
សេដ្ឋកិច្ចខ្ពស់ឡើងវិញ ........................ ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........................ ១៥
— ស្ថានភាពក្នុងប្រទេស ........................ ១៧
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........................ ២៤

---

១ Larry Strange នាយកប្រតិបត្តិ នៃវិទ្យាស្ថាន CDRI ណែនាំបង្ហាញពីសិន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០ នៅក្នុងទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ក្នុងលេខពិសេសនេះ ។

# ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ សូចនាករ ការរំពឹងទុក និង អាទិភាពខាងគោលនយោបាយ

អត្ថបទនេះ ជាសេចក្តីសង្ខេបនៃបទបង្ហាញរបស់លោក John Nelmes[១] ឯកឧត្តម បណ្ឌិត ហង់ ជួនណារ៉ុន[២] និងលោក Stephane Guimbert[៣] ។ អត្ថបទនេះ លើកពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ការរំពឹងទុកសម្រាប់អនាគត និងជម្រើសជាគោលនយោបាយមួយចំនួន ដើម្បីសំរេចបានកំណើនប្រកបដោយចីរភាព ដែលនឹងជួយឲ្យមានការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើនៗ និងជាបន្តក្នុងទូទាំងប្រទេស ។

លោក Nelmes បានធ្វើបទបង្ហាញលើប្រធានបទធំៗមួយចំនួនដូចតទៅ៖

- សេដ្ឋកិច្ចសាកល៖ ការរើបឡើងក្នុងពហុល្បឿន
- សូចនាករនាពេលថ្មីៗរបស់កម្ពុជា៖ តើយើងដើរដល់ណាហើយ?
- ការរំពឹងទុក និងជម្រើសគោលនយោបាយ៖ តើយើងកំពុងដើរទៅណា និងត្រូវជ្រើសយកផ្លូវណា?

ទាក់ទងនឹងសេដ្ឋកិច្ចសាកល លោក Nelmes បានលើកឡើងថា បន្ទាប់ពីបានធ្លាក់ចុះយ៉ាងខ្លាំង សេដ្ឋកិច្ចសាកលកំពុងរើបឡើងវិញ ហើយពាណិជ្ជកម្មក៏ស្ទុះឡើងដែរ ។ ការរើបឡើងជាសាកល បានចាប់ផ្តើមឡើងខ្លាំងក្លាជាងការរំពឹងទុក ទោះបីវាមានសន្ទុះខុសៗគ្នាទៅតាមតំបន់ក្តី ។ លោកបានបញ្ជាក់ថា បើគិតតាមតំបន់ ទ្វីបអាស៊ីនាំមុខគេក្នុងការរើបឡើងវិញនេះ ដោយសារតម្រូវការក្នុងស្រុកមានច្រើន និងការបើកចំហចំពោះពាណិជ្ជកម្មដែលកំពុងរើបឡើង ។ ការរើបឡើងវិញជាសាកលនេះ មានការទ្រទ្រង់ពីការបន្ធូរបន្ថយយ៉ាងខ្លាំងបំផុត នូវគោលនយោបាយខាងសារពើពន្ធ និងរូបិយវត្ថុ ។ ខាងប៉ែកបណ្តាប្រទេសសេដ្ឋកិច្ចជឿនលឿន ពួកគេបានឆ្លងផុតការធ្លាក់ចុះសេដ្ឋកិច្ច ប៉ុន្តែកំណើន ផសស នៅទាបជាខ្លាំងបើធៀបមុនពេលមានវិបត្តិ ។ ម្យ៉ាងទៀត ការរើបសេដ្ឋកិច្ចនេះរំពឹងថានឹងមានសន្ទុះយឺត បើធៀបនឹងល្បឿនធម្មតាកាលពីមុន ដោយសារភាពអត់ការងារធ្វើមានកំរិតខ្ពស់ កំណើនឥណទាននៅខ្សោយដោយហេតុ ធនាគារកំពុងរវល់ជួសជុលតារាងតុល្យការរបស់ខ្លួន និងបំណុលសាធារណៈកំរិតខ្ពស់ ។ លោកបានបង្ហាញថា អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានជួយទ្រទ្រង់ដល់បណ្តាប្រទេសជាសមាជិករបស់ខ្លួននៅអំឡុងពេលមានវិបត្តិ ដោយផ្តល់ជំនួយគាំទ្រហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

សម្រាប់ប្រទេសកម្ពុជា លោកបានបង្ហាញថា សេដ្ឋកិច្ចមានលក្ខណៈវិជ្ជមានជាងកាលពីមុន ក្នុងនេះ (ក) ការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ចមានកំរិតខ្ពស់នៅឆ្នាំ២០០៩ ប៉ុន្តែវិស័យកសិកម្មមានស្ថានភាពល្អ (ខ) សេដ្ឋកិច្ចទំនងជាបានធ្លាក់ចុះដល់កំរិតទាបបំផុតតាំងពីចុងឆ្នាំមុន ហើយឥឡូវនេះកំពុងរើបឡើងវិញ (គ) កំណើនក្នុងឆ្នាំ២០០៩ គឺ -២.៥% ដែលមិនធ្ងន់ធ្ងរដូចការព្យាករណ៍កាលពីមុនរបស់ IMF នោះទេ និង (ឃ) អតិផរណាបានធ្លាក់ចុះយ៉ាងច្រើន ។

សម្រាប់ផលប៉ះពាល់តាមវិស័យ និងអនុវិស័យ លោក Nelmes បានលើកពាក់ព័ន្ធដល់វិស័យមួយចំនួន ដូចជា កាត់ដេរ ទេសចរណ៍ សំណង់ កសិកម្ម ព្រមទាំង ហិរញ្ញវត្ថុផងដែរ ។ វិស័យកាត់ដេរ មានការប៉ះពាល់ធ្ងន់ធ្ងរ ដោយសារតម្រូវការនៅសហរដ្ឋអាមេរិកធ្លាក់ចុះ ប៉ុន្តែការរើបសេដ្ឋកិច្ចអាមេរិក អាចជួយឲ្យវាមានកំណើនវិញ ។ ទោះយ៉ាងនេះក្តី ការប្រកួតប្រជែងខ្លាំងក្លាក្នុងតំបន់ អាចចោទបញ្ហាដល់ការរើបឡើងនៃវិស័យកាត់ដេរ ។ សម្រាប់វិស័យទេសចរណ៍ ចំនួនភ្ញៀវមកដល់កំពុងកើនឡើងវិញ ប៉ុន្តែពួកគេចំណាយលុយតិចជាខ្លាំងជាងឆ្នាំមុន ។ ការធ្លាក់ចុះប្រាក់ចំណូលពីវិស័យទេសចរណ៍ អាចបណ្តាលជាសំខាន់មកពីការផ្លាស់ប្តូរប្រភព ពោលគឺ ប្រទេសដើមរបស់ភ្ញៀវទេសចរ ។ នាបច្ចុប្បន្ន ភ្ញៀវទេសចរមកពីប្រទេសជិតខាងបានកើនឡើង ប៉ុន្តែអំណាចទិញរបស់ពួកគេមានកំរិត ហើយចំនួនភ្ញៀវទេសចរពីបណ្តាប្រទេសអ្នកមានបានធ្លាក់ចុះវិញ ។

នៅកំរិតម៉ាក្រូ អនុមតិគំរោងវិនិយោគបានធ្លាក់ចុះជាខ្លាំង ប៉ុន្តែការផ្លាស់ប្តូរក្នុងប្រភេទគំរោងវិនិយោគ គឺជាសញ្ញាល្អសម្រាប់កំណើនក្នុងរយៈពេលវែង ។ សកម្មភាពសាងសង់រើបឡើងយឺតៗបន្ទាប់ពីបានធ្លាក់ចុះធ្ងន់ធ្ងរ រីឯជំនួញលក់រាយ ក៏កើនឡើងដែរ ។ ការផ្តល់ឥណទានកើនឡើងបន្តិចវិញ បន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុក ដោយសារពីមុនរីកដុះដាលលឿនហួសពេក ។ អតិផរណាធ្លាក់ចុះយ៉ាងខ្លាំង ស្របគ្នានឹងការរួមចុះតម្រូវការ ប៉ុន្តែការឡើងថ្លៃផលិតផល និងការបង្កើនថវិកាចំណាយសាធារណៈនាពេលថ្មីៗបានដាក់សំពាធធ្វើឱ្យវាកើនឡើងវិញ ។

វិស័យកសិកម្មនៅតែមានស្ថានភាពល្អ ដោយសារមួយផ្នែកគឺកំណើនផលិតភាព និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។ ប៉ុន្តែកំណើនក្នុងវិស័យនេះ មិនធំគ្រប់គ្រាន់សំរាប់ប៉ះប៉ូវការធ្លាក់ចុះក្នុងវិស័យឯទៀតៗនោះទេ ។ ការផ្លាស់ប្តូរទាំងអស់ ដែលកើតមានកន្លងមក ធ្វើឲ្យគេរំពឹងថា កំណើន GDP សរុបក្នុងឆ្នាំ២០០៩ មានអត្រាប្រមាណជា - ២.៥% ។ ទោះបីវិស័យកសិកម្ម និងចំណាយសាធារណៈបានកើនឡើងក្តី ប៉ុន្តែវិស័យគន្លឹះៗមួយចំនួនបានរួមចុះ ហើយនាំឱ្យមានការធ្លាក់ចុះជារួមក្នុងសកម្មភាពសេដ្ឋកិច្ច ។

សម្រាប់ការរំពឹងទុក និងជម្រើសគោលនយោបាយ លោក Nelmes បានលើកថា (ក) កំណើននឹងមានអត្រាប៉ាន់ស្មានវិជ្ជមានវិញ ដល់ប្រហែល ៤% ក្នុងឆ្នាំ២០១០ ដោយសារការរើបឡើងវិញនៃសេដ្ឋកិច្ចសាកល (ខ) ការពង្រឹងផ្នែកសារពើពន្ធបានសមស្រប ជាកត្តាគន្លឹះសម្រាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (គ) ការរក្សាការពារសកម្មភាពប្រព័ន្ធហិរញ្ញវត្ថុ ជួយបង្កើនលទ្ធភាពទទួល

---

១ តំណាងនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រចាំប្រទេសកម្ពុជា ។

២ រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានអចិន្ត្រៃយ៍ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI ។

៣ សេដ្ឋវិទូជាន់ខ្ពស់នៃធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា ។

បានហិរញ្ញប្បទាន និង (ឃ) កំណែទម្រង់រចនាសម្ព័ន្ធកាន់តែស៊ីជម្រៅ អាចជួយបង្កើនសក្តានុពល មានកំណើនក្នុងរយៈពេលវែង ។

លោក Nelmes បានអះអាងពីការរំពឹងទុកថា កំណើនអាចស្ទុះឡើងថែមទៀតរហូតដល់ជាង ៤% នៅឆ្នាំ២០១០ ប្រសិនបើវិស័យកសិកម្មនៅតែមានកំណើនថេរ ស្ថានភាពក្នុងសាកលលោកប្រែប្រួលប្រសើរឡើងទៀត ហើយ តម្រូវការក្នុងស្រុកក៏រើបឡើងវិញ ។ ឱនភាពថវិកាដែលធូរស្រាលឡើង ក៏ជាកត្តាមួយជួយដល់សេដ្ឋកិច្ចដែរ ។ ឱនភាពថវិកាឆ្នាំ២០១០ រំពឹងថាមានកំរិត ៥.២៥% នៃ ផសស ហើយលោកបានវែកញែកថា ឱនភាពកំរិតទាបជាងនេះអាចសមស្របល្អ ប៉ុន្តែគួរជៀសវាងការប្រើហិរញ្ញប្បទាន អំពីប្រព័ន្ធធនាគារក្នុងស្រុក ។ លោកបានលើកសរសើរលទ្ធផលប្រមូលប្រាក់ចំណូលរបស់រាជរដ្ឋាភិបាលនៃកម្ពុជាក្នុងឆ្នាំ២០០៩ ហើយបានអះអាងថា កិច្ចប្រឹងប្រែងជាបន្តក្នុងឆ្នាំ២០១០ អាចលុបបំបាត់តម្រូវការប្រើហិរញ្ញប្បទានក្នុងស្រុក និងបើកឱកាសសម្រាប់ការបង្កើនចំណាយអភិវឌ្ឍន៍ជាអាទិភាពច្រើនថែមទៀត ។

ទាក់ទិននឹងវិស័យហិរញ្ញវត្ថុ និងធនាគារ លោក Nelmes បានជជែកវែកញែកឲ្យមានការត្រួតពិនិត្យខ្លាំងជាបន្តទៀត លើវិស័យធនាគារ និងការពង្រឹងអនុវត្តវិធានប្រុងប្រយ័ត្ន ដើម្បីធានាស្ថិរភាព និងជួយសម្រួលបង្កើនលទ្ធភាពទទួលបានហិញ្ញប្បទាន ។ លោកបានចង្អុលបង្ហាញថា ប្រព័ន្ធធនាគារបច្ចុប្បន្ន មានប្រើសាច់ប្រាក់ច្រើនណាស់ ប៉ុន្តែប្រាក់ចំណេញមានតិច ដោយសារអប្បហារអត្រាការប្រាក់អវិជ្ជមាន ។ លោកបានដាស់តឿនដល់អាជ្ញាធរខាងវិស័យធនាគារ ឱ្យជៀសវាងកំណើនច្រើនៗដូចមុនទៀតនៃការផ្តល់កំចី ដើម្បីកាត់បន្ថយហានិភ័យនៃការដួលរលំតាមក្រោយ ។

សម្រាប់រយៈពេលវែង លោក Nelmes ផ្តល់មតិថា កំណើនរឹងមាំមានចីរភាព អាចជួយឲ្យកម្ពុជាឡើងឋានៈជាប្រទេសមានចំណូលមធ្យម ។ ប៉ុន្តែដើម្បីធានាឲ្យកំណើនមានចីរភាព ត្រូវប្រឹងប្រែងបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពធនធានមនុស្ស ដែលជាកត្តាមូលដ្ឋានសំរាប់ការឡើងឋានៈនៅក្នុងអាស៊ាន ។ ដើម្បីមានកំណើនលឿនជាងប្រទេសជិតខាងក្នុងរយៈពេលវែង ត្រូវមានយុទ្ធសាស្ត្រធំទូលាយ បង្កើនសមត្ថភាពប្រកួតប្រជែង ។ ដើម្បីសម្រេចគោលដៅនេះ IMF បានជួយដល់រាជរដ្ឋាភិបាលក្នុងវិស័យមួយចំនួន ដូចជា៖

- ការផ្តល់មតិប្រឹក្សាលើគោលនយោបាយ សម្រាប់វិស័យហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ក្រោមការពិនិត្យតាមដានរបស់ IMF
- ជំនួយបច្ចេកទេស ដូចជា
  - ឧបករណ៍ និងក្របខណ្ឌ សម្រាប់គោលនយោបាយរូបិយវត្ថុ
  - ការពង្រឹងការពិនិត្យតាមដានក្នុងវិស័យធនាគារ
  - កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
  - វគ្គបណ្តុះបណ្តាលជំនាញឯកទេស ក្នុងការបង្កើតគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដើម្បីកសាងសមត្ថភាពធនធានមនុស្ស ។

បណ្ឌិត ហង់ ជួន ណារ៉ុន បានធ្វើបទបង្ហាញជាបន្ត ដោយបានបកស្រាយលើគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍសេដ្ឋកិច្ច ដូចជាការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច គោលនយោបាយជាអាទិភាព សម្រាប់កំណើន ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍវិស័យឯកជន និងការគ្រប់គ្រងធនធានធម្មជាតិ ។ អត្ថបទនេះ មានបង្ហាញដោយសង្ខេបពីបញ្ហាផ្សេងៗ ទាក់ទងនឹងគោលនយោបាយជាអាទិភាព សម្រាប់កំណើនការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ។

ជាបឋម បណ្ឌិត ណារ៉ុន បានបូកសរុបពីសក្តានុពលកំណើនរបស់កម្ពុជា ដែលមានជាអាទិ៍៖

- ដីអាចដាំដុះដ៏សំបូរ ដែលជាសក្តានុពលសម្រាប់ការអភិវឌ្ឍ និងពិពិធកម្ម ផលិតកម្មកសិកម្ម ដូចជា ការកែច្នៃកសិផលជាដើម ។ កំណើនផលិតកម្ម ជាពិសេសផលិតកម្មផលដំណាំសំខាន់ៗ ដូចជា ស្រូវ អាចបំរើដល់ការនាំចេញ ។ គោលនយោបាយរបស់សហភាពអឺរ៉ុប (EU) ស្តីពី "អ្វីទាំងអស់ក្រៅពីអាវុធ" ក៏ដូចជាការនាំចេញស្រូវដោយមិនជាប់ពន្ធទៅបណ្តាប្រទេស EU បានផ្តល់ទីផ្សារមានចំណេញច្រើនដល់កម្ពុជា ។ ប៉ុន្តែដើម្បីសំរេចសក្តានុពលនេះបាន ត្រូវដោះស្រាយកត្តារាំងស្ទះផលិតកម្មកសិកម្ម និងត្រូវផ្តល់អាទិភាពដល់ការវិនិយោគបន្ថែមលើធារាសាស្ត្រ និងការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសនៅតំបន់ជនបទ ។
- ពលកម្មតម្លៃថោកនៅសំបូរច្រើន តែមានជំនាញទាប ។ ដូចក្នុងផ្នែកកាត់ដេរដែរ គេអាចប្រើប្រាស់អតិរេកពលកម្មក្នុងផលិតកម្មឧស្សាហកម្មមួយចំនួន ។ ប៉ុន្តែក្នុងរយៈពេលវែង គួរយកចិត្តទុកដាក់ ជាពិសេសលើការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រសិនបើកម្ពុជាចង់សំរេចបានកំណើនប្រកបដោយចីរភាព និងបានដល់គ្រប់ៗគ្នា ដើម្បីអាចដើរទាន់បណ្តាប្រទេសជិតខាងខ្លួន ។
- កេរ្តិ៍ដំណែលវប្បធម៌ និងជីវចំរុះធម្មជាតិដ៏សំបូរ ដែលផ្តល់ឱកាសល្អ សម្រាប់ការពង្រឹងវិស័យទេសចរណ៍ និងទទួលផលចំណេញបានកាន់តែច្រើនពីទេសចរណ៍អន្តរជាតិ ។
- ធនធានរ៉ែ ប្រេងកាត និងឧស្ម័ន មិនទាន់បានទាញយកផល និងប្រើប្រាស់យ៉ាងសក្តិសិទ្ធិ ដើម្បីបង្កើតប្រាក់ចំណូលដែលកំពុងមានតម្រូវការជាខ្លាំង សម្រាប់ការអភិវឌ្ឍប្រទេសទៅតាមបទពិសោធន៍របស់ប្រទេសមួយចំនួនដែលបានអភិវឌ្ឍលឿននៅក្នុងតំបន់ ។

លោក ណារ៉ុន បានលើកនូវគោលនយោបាយប្រាំមួយមុខព្រួញ សម្រាប់ធ្វើឲ្យសក្តានុពលកំណើនក្លាយជាការពិត គឺមាន ១- ការអភិវឌ្ឍធនធានមនុស្ស ២- ការអភិវឌ្ឍកសិកម្ម ៣- ទេសចរណ៍ (ចាប់ពីទេសចរណ៍វប្បធម៌ទៅដល់ទេសចរណ៍ឆ្នេរសមុទ្រ) ៤- ហេដ្ឋារចនាសម្ព័ន្ធ (ទាំងផ្នែកក្របខ័ណ្ឌច្បាប់ និងផ្នែករូបវន្ត) ៥- ឧស្សាហកម្មកំពុងផុសឡើង និង ៦- ឧស្សាហកម្មកែច្នៃ ។ ដើម្បីអនុវត្តគោលនយោបាយនេះ ត្រូវមានអាទិភាពមួយចំនួននៅកំរិតម៉ាក្រូ/ហិរញ្ញវត្ថុ កំរិតហិរញ្ញវត្ថុ ក៏ដូចជា កំរិតសហគ្រាស ។

នៅកំរិតម៉ាក្រូ/ហិរញ្ញវត្ថុ ត្រូវផ្តល់អាទិភាពដល់ការធ្វើឱ្យមានកំណើនឡើងវិញ ព្រមទាំងការរក្សាស្ថិរភាព ។ ការធ្វើឱ្យមានកំណើនឡើងវិញ អាចសំរេចបានតាមការគួបផ្សំគ្រឿងជំរុញខាងហិរញ្ញវត្ថុ គោលនយោបាយរូបិយវត្ថុ និងការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ ។

នៅកំរិតនេះ គោលនយោបាយគួរសំដៅជួយបង្កើនភាពប្រកួតប្រជែង (តួនាទីជាគោលនយោបាយអត្រាការប្រាក់ នៃគោលនយោបាយពន្ធដា) និងការកៀងគរប្រាក់សន្សំក្នុងស្រុក ។

នៅកំរិតហិរញ្ញវត្ថុ គោលនយោបាយគួរផ្តោតលើការបង្កើតឱកាសហិរញ្ញវត្ថុថ្មីៗ (ពន្ធ និងមិនមែនពន្ធ ព្រមទាំងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)) ។ ការចំណាយ គួរផ្តោតលើកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ (ការថែទាំ ជួសជុល) និងការអប់រំ ។ មានបញ្ហាជាច្រើនជាប់ទាក់ទងនឹងគុណភាពនៃការចំណាយ និងប្រព័ន្ធសុវត្ថិភាពសង្គម ដែលគួរគិតគូរពិចារណាយ៉ាងប្រយ័ត្នប្រយែង ។ ម្យ៉ាងទៀត ក៏គួរមានកំណែទម្រង់រដ្ឋបាលសាធារណៈ សម្រាប់ការលើកកម្ពស់សមត្ថភាពអនុវត្តដែរ ។

នៅកំរិតសហគ្រាស កំណែទម្រង់ខាងច្បាប់ និងការសម្របសម្រួលពាណិជ្ជកម្ម (ជាពិសេសក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជិតខាង) ក៏គួរផ្តល់អាទិភាពខ្ពស់ដែរ ។ នៅកំរិតគោលនយោបាយ គួរប្រឹងប្រែង ធ្វើឲ្យគោលនយោបាយឧស្សាហកម្មអាចអនុវត្តបាន ។ ដើម្បីសំរេចរឿងនេះ គួរតាមដាន និងវាយតម្លៃលើគោលនយោបាយដែលបានដាក់អនុវត្ត (ឧ. ដូចជា SEZs, ELCs, ជាដើម) និងដាក់អនុវត្តឧបករណ៍ថ្មីៗទៀត (ឧ. កន្លែងផាត់ទាត់សម្រាប់វិនិយោគិនខាងកសិពាណិជ្ជកម្ម កំរិតស្តង់ដារផ្សេងៗ ការសំរបសំរួលតាមវិស័យជាដើម) ។ វិស័យផ្សេងទៀត ដែលគួរត្រួតពិនិត្យ និងតាមដានឲ្យជិតដល់ រួមមាន តួនាទី និងលក្ខណៈនៃវិនិយោគផ្ទាល់ពីបរទេស ក៏ដូចជាការជួបពិភាក្សារវាងវិស័យសាធារណៈ-ឯកជន (ឧ. វេទិកាវិស័យសាធារណៈ-ឯកជន) ។

បណ្ឌិត ណារ៉ុន បានលើកថា ពិពិធកម្មនៃសេដ្ឋកិច្ចកម្ពុជា ជាកត្តាគន្លឹះ សម្រាប់ពង្រីកមូលដ្ឋានកំណើននៅក្នុងប្រទេស និងធានាឲ្យកំណើនមានចីរភាពល្អ ។ ក្រៅពីពិពិធកម្មដែលទន់ខ្សោយ ឬមានកំរិតការនាំចេញរបស់កម្ពុជា ក៏មិនសូវទំនើប (ឧទាហរណ៍ខ្សែរយៈកំណត់តម្លៃបែបធម្មតាៗ) ហើយកម្ពុជា ក៏មិនមានស្ថានភាពល្អទេនៅលើទីផ្សារអន្តរជាតិ ។ លោកបណ្ឌិតអះអាងថា កម្ពុជាមានឧត្តមភាពប្រៀបធៀបជា ដីធ្លីដ៏សំបូរ ពលកម្មថោកក្នុងតំបន់ ហើយកត្តាទាំងនេះគួររក្សាឲ្យបាន ។ ពិពិធកម្មគួរសំរេចឲ្យបានក្នុងឧស្សាហកម្មដែលមានស្រាប់ ដូចជាតាមរយៈពិពិធកម្មក្នុងទីផ្សារ និងការបង្កើនសកម្មភាពពាណិជ្ជកម្មក្នុងតំបន់ ។ ការយកកសិ-ពាណិជ្ជកម្មធ្វើជាមធ្យោបាយឈានទៅផលិតទំនិញថ្មីៗ ក៏គួរគិតគូរវាយតំលៃយ៉ាងប្រុងប្រយ័ត្នដែរ ។

ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ជាកត្តាគន្លឹះមួយទៀតនៃគោលនយោបាយ ដើម្បីសំរេចសក្តានុពលកំណើនរបស់កម្ពុជាឲ្យបាន ។ ដើម្បីអាចប្រកួតប្រជែងក្នុងពិភពលោកដែលកាន់តែបើកចំហ និងធ្វើសេរីភាវូបនីយកម្ម ត្រូវមានជាសំខាន់នូវធនធានមនុស្ស ។ រឿងនេះ អាចសំរេចបានតាមរយៈ ការបង្កើតវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ។ ដោយសារមានពិពិធកម្មឧស្សាហកម្ម ការងារមួយដែលកាន់តែសំខាន់ឡើង គឺត្រូវពង្រឹងយន្តការដោះស្រាយវិវាទការងារដែលមានស្រាប់ ដូចជា ក្រុមប្រឹក្សាមជ្ឈត្តកម្ម គណៈកម្មការដោះស្រាយកូដកម្មនៅគ្រប់កំរិត ការបណ្តុះបណ្តាលអ្នកសំរុះសំរួលស្ម័គ្រចិត្តក្នុងជួរអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយវិវាទការងារដោយសន្តិភាព និងធានាឲ្យការងារមានចីរភាព ។

តមកទៀត បណ្ឌិត ណារ៉ុន បានពិចារណាពីសក្តានុពលសម្រាប់កំណើនវិស័យកសិកម្ម ដែលអាចសំរេចបានតាមរយៈយុទ្ធសាស្ត្រវិស័យកសិកម្មមួយដ៏សក្តិសិទ្ធិ ។ លោកបានវែកញែកថា យុទ្ធសាស្ត្រនេះ ត្រូវមានរួមបញ្ចូលនូវសមាសធាតុដូចខាងក្រោម៖

- បង្កើនផលិតភាពកសិកម្ម តាមរយៈ
  - វិនិយោគលើសំណង់ធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទ
  - ការបង្កើនការប្រើប្រាស់ជី រីកសិកម្មសរីរាង្គ
  - ការបង្កើនការស្រាវជ្រាវ និងការផ្សព្វផ្សាយបច្ចេកទេស
  - ការបង្កើនលទ្ធភាពទទួលបានឥណទាន
- ការសំរបសំរួល និងការតភ្ជាប់កសិករកម្ពុជា ទៅនឹងខ្សែរយៈកំណត់តម្លៃម្ហូបអាហារសាកល
- គោលនយោបាយដើម្បីបង្កើនការនាំចេញកៅស៊ូ និងស្រូវ

ក្រាហ្វិក ១: ការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់ពិត



ក្រាហ្វិក ២: កត្តារាំងស្ទះដ៏ធ្ងន់ធ្ងរ (% នៃសហគ្រាសដែលបានរាយការណ៍ថាកត្តាទាំងនោះមានកំរិតធ្ងន់ធ្ងរ)




- ចង្កោមផលិតផលកសិកម្ម៖ ខ. វារីវប្បកម្មផ្សារភ្ជាប់ជាមួយការឧស្សាហកម្មផលិតចំណីត្រី និង ចំណីសត្វ ។

ពាក់ព័ន្ធនឹងប្រធានបទស្រដៀងគ្នានេះដែរ លោក Giumbert បានបង្ហាញដោយសង្ខេបនូវការសិក្សានាពេលថ្មីៗមួយ របស់ធនាគារពិភពលោក[៤] ស្តីពីកំណើនព្យាករណ៍សម្រាប់កម្ពុជា ។ ដំបូងលោកបានលើកពីចំណុចមួយ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដែលចែងថា "ក្នុងទិសដៅជានាក់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ដែលជាបុរេលក្ខខណ្ឌនៃការបង្កើតការងារ និងបង្កើនប្រាក់ចំណូលរបស់ប្រជាជន រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តវិធានការពិពិធភាវូបនីយកម្ម សេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា តាមរយៈការបង្កើតបរិស្ថានអនុគ្រោះដល់ការវិនិយោគ ទាំងវិស័យ សាធារណៈ ទាំងវិស័យឯកជន (ទាំងក្នុងស្រុក និងទាំងបរទេស) សម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ ដូចតទៅ៖ (១) កសិកម្ម (២) ទឹក និងប្រព័ន្ធធារាសាស្ត្រ (៣) ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (៤) អគ្គិសនី (៥) ការអភិវឌ្ឍធនធានមនុស្ស (៦) ឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មផលិតទំនិញនាំចេញ (៧) ទេសចរណ៍ (៨) អាជីវកម្មប្រេងកាត ឧស្ម័នធម្មជាតិ និងរ៉ែដទៃទៀត (៩) បច្ចេកវិទ្យាព័ត៌មានគមនាគមន៍ (១០) ពាណិជ្ជកម្ម (វាក្យខណ្ឌទី៤០ នៃយុទ្ធសាស្ត្រ ទំព័រ៣៨) ។ តទៅនេះ គឺជាសេចក្តីសង្ខេបនៃបញ្ហានានា ដែលលោកបានលើកមកវែកញែកទាក់ទងនឹងពាណិជ្ជកម្ម និងការសម្របសម្រួលពាណិជ្ជកម្ម ។

សម្រាប់ភាពប្រកួតប្រជែងខាងពាណិជ្ជកម្ម កត្តាគន្លឹះមួយចំនួន មានតួនាទីសំខាន់ ដូចជាការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់ពិតធៀបនឹងដៃគូប្រកួតប្រជែង ក៏ដូចជាកត្តារាំងស្ទះខាងទីផ្សារ ដែលពាណិជ្ជករកំពុងជួបប្រទះ ។ សម្រាប់ភាពប្រកួតប្រជែងខាងអត្រាប្តូរប្រាក់ ដូចមានបង្ហាញក្នុងក្រាហ្វិក១ នេះ កម្ពុជាបានបាត់បង់ភាពប្រកួតប្រជែងខ្លះហើយ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ រឿងនេះជាប់ទាក់ទងនឹងសេដ្ឋកិច្ចប្រើប្រាក់ដុល្លាររបស់កម្ពុជា និងការឡើងថ្លៃប្រាក់ដុល្លារក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយ ។

កត្តារាំងស្ទះសំខាន់ៗដល់កំណើន ភាពប្រកួតប្រជែង និងជាពិសេសពាណិជ្ជកម្ម បើតាមសេចក្តីសង្ខេបនៃការសិក្សាដែលបានលើកឡើង រួមមាន៖

- ការសម្របសម្រួលនៃខ្សែរយៈកំណត់តម្លៃ
- បទបញ្ញត្តិច្បាប់ស្មុគស្មាញ/ប្រាក់កំរៃក្រៅផ្លូវការ
- អគ្គិសនី
- ពាណិជ្ជកម្ម និងការផ្គត់ផ្គង់ឡូហ្សីស្ទិក

ដូចមានបង្ហាញក្នុងក្រាហ្វិក ២ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ទោះបីកត្តារាំងស្ទះភាគច្រើនហាក់ដូចបានថយចុះ ក្នុងនេះមានទាំងកត្តារាំងស្ទះដ៏ធ្ងន់ធ្ងរបំផុត ដែលជាប់ទាក់ទងនឹងអំពើពុករលួយនោះផង ប៉ុន្តែក៏មានកត្តាមួយចំនួន ដូចជា បទបញ្ញត្តិខាងពាណិជ្ជកម្ម និងគយ ជាដើម ដែលហាក់ដូចជាកាន់តែរាំងស្ទះខ្លាំងឡើង ។

[៤] ធនាគារពិភពលោក (២០០៩) ការធ្វើឱ្យមានចីរភាពនូវកំណើនឆាប់រហ័សក្នុងបរិយាកាសដែលមានភាពប្រឈម អនុស្សារណៈសេដ្ឋកិច្ចប្រទេសកម្ពុជា ២០០៩ ។

# ជំរុញការនាំចេញមាសស របស់កម្ពុជា[១]

## សេចក្តីផ្តើម

សេដ្ឋកិច្ចកម្ពុជាកើនឡើងយ៉ាងលឿនក្នុងទសវត្សរ៍កន្លងទៅ ។ ពីឆ្នាំ ១៩៩៨-២០០៨ ផសស របស់កម្ពុជា កើនបាន ៩,១% ក្នុងមួយឆ្នាំៗ ។ មានការមូលមតិថា កំណើនដ៏ខ្ពស់នេះ ជំរុញឡើងជាសំខាន់ដោយវិស័យ កាត់ដេរ សំណង់ និងទេសចរណ៍ ។ ទោះយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជាភាគច្រើន នៅតែពឹងផ្អែកលើកសិកម្មនៅតាមទីជនបទនៅឡើយ ។ ទោះបីចំណែករបស់កសិកម្មក្នុង ផសស បានធ្លាក់ចុះជាបណ្តើរៗក្តី ក៏ក្នុងឆ្នាំ២០០៨ វានៅមានចំណែកដល់ ២៦% ក្នុង ផសស និងបានផ្តល់ការងារដល់ជាង ៥៦% នៃកំលាំងពលកម្មសរុបនៅកម្ពុជា ។ ប្រហែល ៨០% នៃប្រជាជនកម្ពុជាសព្វថ្ងៃរស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្ម ។

ជាមធ្យម វិស័យកសិកម្មមានកំណើនទាបជាង វិស័យឧស្សាហកម្ម និងសេវាកម្ម ។ ពីឆ្នាំ១៩៩៨-២០០៨ វិស័យកសិកម្មមានអត្រាកំណើនប្រមាណ ៤,២% ក្នុង១ឆ្នាំ ធៀបនឹង ៩,៩% សំរាប់វិស័យសេវាកម្ម និង ១៤,២% សំរាប់វិស័យឧស្សាហកម្ម ។ ក្នុងទសវត្សរ៍២០០០ កំណើនវិស័យកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំបានឡើងចុះមិនទៀងទាត់ជាខ្លាំង ហើយជួនកាលមានកំណើនអវិជ្ជមានទៀតផង ក្នុង ៥ឆ្នាំ ដើមទសវត្សរ៍២០០០ ប៉ុន្តែចាប់ពីឆ្នាំ២០០៥ មក វាមានកំណើនវិជ្ជមានជាប់រហូត ។ នៅឆ្នាំ២០០៩ កំណើនវិស័យកសិកម្ម មានប្រហែល ៥% ស្របពេលដែលកំណើន ប៉ាន់ស្មាននៃ ផសស ស្ថិតនៅក្នុងចន្លោះពី -២,២% ដល់ +០,១% ។

ដោយសារមានអាកាសធាតុតំបន់ត្រូពិច សំបូរដីដាំដុះ និងមានកំលាំងពលកម្មគ្មានជំនាញច្រើន កម្ពុជាមានឧត្តមភាពក្នុងវិស័យកសិកម្ម ។ គេទទួលស្គាល់ជាទូទៅថា ការជំរុញវិស័យកសិកម្ម (កសិឧស្សាហកម្ម) ជាយុទ្ធសាស្ត្រល្អបំផុត សំរាប់ពង្រីកមូលដ្ឋានសេដ្ឋកិច្ច ទប់ទល់ការប៉ះទង្គិចខាងម៉ាក្រូសេដ្ឋកិច្ច ធានាសន្តិសុខស្បៀង កែលំអជីវភាពប្រជាជននៅតាមជនបទ និងកាត់បន្ថយភាពក្រីក្រ ។

ផលដំណាំមានចំណែកធំបំផុតក្នុងវិស័យកសិកម្ម បន្ទាប់មកគឺ ផលនេសាទ សត្វចិញ្ចឹម និងផលពីព្រៃឈើ ។ នៅឆ្នាំ២០០៨ ផលដំណាំមានចំណែក ៥៣% នៃផលិតផលកសិកម្ម ឬកើនឡើង ១២ឯកតាភាគរយ ធៀបនឹងឆ្នាំ១៩៩៨ (12 points more than in 1998) ហើយកំណើននេះ បានមួយផ្នែកមកពីការធ្លាក់ចុះនៃផលនេសាទ និងផលពីព្រៃឈើ ។ ផលិតផលកសិកម្មចំបងៗ គឺមាន ស្រូវ ពោត ដំឡូងឈើ សណ្តែកសៀង ថ្នាំជក់ និងកៅស៊ូ ។ ស្រូវអង្ករ ជាអាហារមូលដ្ឋាននៅកម្ពុជា និងមានចំណែកជាមធ្យម ៥៥%

១ លោក តុង គឹមស៊ុន អ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI បានពិនិត្យឡើងវិញ ពីការអភិវឌ្ឍកសិកម្មនៅកម្ពុជា ដោយផ្តោតលើផលិតកម្ម និងការនាំចេញស្រូវ ។ លោកឧកញ៉ា ភូ ពុយ ប្រធានសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា បានផ្តល់ជាមតិយោបល់ ស្តីពីសក្តានុពលយ៉ាងច្រើនរបស់កម្ពុជាក្នុងការកិនស្រូវ និងនាំចេញអង្ករ ។

តារាង ១: ផលិតភាពស្រូវឆ្នាំ១៩៩៤-២០០៨ (តោន/ហិកតា)

| | ប្រ៊ុយណេ | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | ភូមា | ហ្វីលីពីន | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|---|---|
| 1994 | 1.67 | 1.49 | 4.35 | 2.58 | 3.06 | 3.17 | 2.89 | 2.35 | 3.57 |
| 1995 | 1.64 | 1.79 | 4.35 | 2.53 | 3.16 | 2.98 | 2.80 | 2.42 | 3.69 |
| 1996 | 1.65 | 1.81 | 4.42 | 2.55 | 3.25 | 3.06 | 2.86 | 2.41 | 3.77 |
| 1997 | 1.65 | 1.77 | 4.43 | 2.76 | 3.07 | 3.08 | 2.93 | 2.38 | 3.88 |
| 1998 | 1.65 | 1.79 | 4.20 | 2.71 | 2.88 | 3.13 | 2.70 | 2.47 | 3.96 |
| 1999 | 0.53 | 1.94 | 4.25 | 2.93 | 2.94 | 3.24 | 2.95 | 2.42 | 4.10 |
| 2000 | 0.65 | 2.12 | 4.40 | 3.06 | 3.06 | 3.38 | 3.07 | 2.61 | 4.24 |
| 2001 | 0.73 | 2.07 | 4.39 | 3.13 | 3.11 | 3.42 | 3.19 | 2.62 | 4.29 |
| 2002 | 0.73 | 1.92 | 4.47 | 3.27 | 3.24 | 3.42 | 3.28 | 2.61 | 4.59 |
| 2003 | 0.79 | 2.10 | 4.54 | 3.14 | 3.36 | 3.55 | 3.37 | 2.65 | 4.64 |
| 2004 | 0.82 | 1.98 | 4.54 | 3.28 | 3.33 | 3.79 | 3.51 | 2.86 | 4.86 |
| 2005 | 0.87 | 2.48 | 4.57 | 3.49 | 3.42 | 3.75 | 3.59 | 2.96 | 4.89 |
| 2006 | 1.22 | 2.49 | 4.62 | 3.35 | 3.39 | 3.80 | 3.68 | 2.92 | 4.89 |
| 2007 | 1.20 | 2.62 | 4.71 | 3.47 | 3.53 | 3.84 | 3.80 | 3.01 | 4.99 |
| 2008 | 1.20 | 2.75 | 4.89 | 3.47 | 3.57 | 3.72 | 3.77 | 2.97 | 5.22 |
| មធ្យមភាគ | 1.13 | 2.07 | 4.47 | 3.05 | 3.23 | 3.42 | 3.23 | 2.64 | 4.37 |
| អត្រាកំណើន | 1.67 | 4.84 | 0.88 | 2.21 | 1.16 | 1.20 | 2.00 | 1.73 | 2.78 |

*ប្រភព: FAO*

នៃផលិតផលកសិកម្មសរុប ឬ ៩% នៃ ផសស ក្នុងអំឡុងឆ្នាំ១៩៩៤-២០០៦ ។

## ផលិតកម្មស្រូវ

ពីឆ្នាំ១៩៩៤ ដល់ ២០០៨ ផលិតកម្មស្រូវកើនឡើងទ្វេដង ដោយសារកំណើនផលិតភាព និងផ្ទៃដីដាំដុះ ប៉ុន្តែនៅចុងទសវត្សរ៍ ១៩៩០ វាមានអត្រាកំណើនជាមធ្យមកម្រិតទាបត្រឹម ១% ហើយ ចាប់ពីឆ្នាំ២០០២ មក អត្រាកំណើននេះ ប្រែប្រួលឡើងចុះខ្លាំងណាស់ ។ ផលិតកម្មស្រូវ ពឹងផ្អែកជាខ្លាំងលើអាកាសធាតុ ។ តួយ៉ាងក្នុងឆ្នាំ២០០៤ ផលស្រូវសរុបមាន ៤,១លានតោន ឬ ធ្លាក់ចុះ ១១% បើធៀបនឹងឆ្នាំ២០០៣ ដោយសារមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរនៅតាមខេត្តជាច្រើន (NIS 2008) ។ នៅឆ្នាំ២០០៥ ផលិតកម្មស្រូវ ឡើងខ្ពស់បំផុតដល់ ៥,៩លានតាន ឬ កើន ៤៤% ធៀបនឹងឆ្នាំ២០០៤ ដោយសារអាកាសធាតុអំណោយផលល្អ និង ទិន្នផលទាបខុសប្រក្រតី ក្នុងឆ្នាំ២០០៤ ដែលបង្កឡើងដោយគ្រោះរាំងស្ងួត ។

ជាមធ្យម ទិន្នផលស្រូវក្នុងមួយហិកតា កើន ៤,៨% ក្នុងមួយឆ្នាំ ដែលជាអត្រាខ្ពស់បំផុត ធៀបនឹងប្រទេសជិតខាងកម្ពុជា ។ ទិន្នផលស្រូវកើនពី ១,៤៩តោន/ហិកតា នៅឆ្នាំ១៩៩៤ ដល់ ២,៧៥តោន/ហិកតា នៅឆ្នាំ២០០៨ (តារាង ១) ។ កំណើននេះ ឆ្លុះបញ្ចាំងពីលទ្ធភាពកាន់តែប្រសើរក្នុងការមានជី និងធាតុចូលផ្សេងទៀតប្រើប្រាស់ ជាជាងការប្រើពូជស្រូវទិន្នផលខ្ពស់ (Agrifood Consulting International 2006, cited in Yu & Fan 2009) ។ ទោះបីមានកំណើនបែបនេះក្ដី កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសមានផលិតភាពស្រូវទាបបំផុតក្នុងតំបន់អាស៊ីខាងត្បូង អាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត ។ ទិន្នផលទាបនេះ បណ្ដាលមួយផ្នែកពីផលិតភាពដីទាប ដែលបង្ហាញពីតម្រូវការកែលំអបន្ថែមនូវបច្ចេកវិទ្យាផលិតកម្ម (Yu & Fan 2009) ។ ទិន្នផលទាបនាបច្ចុប្បន្នក៏បង្ហាញដែរថា កម្ពុជានៅមានសក្ដានុពលច្រើន សំរាប់បង្កើនផលិតកម្មកសិកម្ម ដូច្នេះ ការបង្កើនទិន្នផលស្រូវ គួរកំណត់ថាជាប្រភពដ៏សំខាន់មួយនៃកំណើនវិស័យកសិកម្ម ។

## តម្រូវការក្នុងស្រុកជាអង្ករសំរាប់បរិភោគ និងអង្ករសំរាប់នាំចេញ

គេប៉ាន់ស្មានថា តំរូវការអង្កររបស់ប្រជាជនកម្ពុជា មានប្រហែល ១៤៣គីឡូក្រាម/នាក់/ឆ្នាំ (MAFF 2009) ។ ដូច្នេះ យោងតាមចំនួនប្រជាជនសរុបប៉ាន់ស្មាន (NIS 2008) តម្រូវការក្នុងស្រុកសរុបនូវអង្ករ កើនឡើងពី ១,៤លានតោន (ស្មើនឹង ២,២លានតោនស្រូវ) ក្នុងឆ្នាំ១៩៩៤ ដល់ ២,១លានតោន (ស្មើនឹង ៣,៣លានតោនស្រូវ) ក្នុងឆ្នាំ២០០៨ ។ នៅឆ្នាំ១៩៩៥ ផលិតកម្មស្រូវកើនដល់កម្រិតគ្រប់គ្រាន់ សំរាប់តម្រូវការក្នុងស្រុក ហើយអតិរេកស្រូវបានកើនជាខ្លាំងក្នុងរយៈពេលបីឆ្នាំចុងក្រោយ រហូតដល់ ២,៨លានតោន (ឬ ១,៦លានតោនអង្ករ) នៅក្នុងឆ្នាំ២០០៨ ។

កម្ពុជា ចាប់ផ្ដើមនាំចេញអង្ករឡើងវិញនៅឆ្នាំ១៩៩៥ (Hing et al. 2007) បន្ទាប់ពីបានផ្អាកអស់ ២០ឆ្នាំ ដោយសារសង្គ្រាម និងភាពឯកោខាងនយោបាយ ។ ទោះយ៉ាងនេះក្ដី ទិន្នន័យអង្ករនាំចេញ

ក្រាហ្វិក ១: តម្រូវការក្នុងស្រុកនូវអង្ករ ឆ្នាំ១៩៩៤-២០០៨




*ប្រភព: ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើ IS (2008)*

តារាង ២: ការនាំចេញអង្ករឆ្នាំ២000-0៨

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2000-2008 |
|---|---|---|---|---|---|---|---|---|---|
| អង្ករនាំចេញ (ពាន់តោន) | 15.02 | 15.50 | 2.28 | 4.94 | 5.98 | 5.72 | 4.37 | 6.39 | 6.74 |
| អង្ករនាំចេញ (ពាន់តោន នៃបរិមាណស្រូវ) | 23.84 | 24.61 | 3.62 | 7.83 | 9.50 | 9.08 | 6.93 | 10.14 | 10.70 |
| អតិរេកស្រូវ (ពាន់តោន) | 812 | 518 | 1,234 | 723 | 2,257 | 2,453 | 2,618 | 2,620 | 1,561 |
| ប្រាក់ចំណូលសក្តានុពលទទួលបានពីការនាំចេញ (លានដុល្លារ)* | 76 | 55 | 130 | 97 | 341 | 383 | 485 | 857 | |
| ប្រាក់ចំណូលសក្តានុពលទទួលបានពីការនាំចេញ (លានដុល្លារ)** | 88 | 62 | 152 | 108 | 405 | 471 | 541 | 1,089 | |
| អង្ករនាំចេញ ធៀបនឹងអតិរេកអង្ករ | 0.029 | 0.048 | 0.003 | 0.011 | 0.004 | 0.004 | 0.003 | 0.004 | 0.01 |

*សំគាល់: * ថ្លៃអង្ករនាំចេញ (Viet25-FOB) * * ថ្លៃអង្ករនាំចេញ (Thai5-FOB)*

*ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; IS (2008)*

ជាផ្លូវការសំរាប់ឆ្នាំ២000-0៨ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បង្ហាញនូវបរិមាណអង្ករនាំចេញដ៏តិចតួច ដែលមិនឆ្លុះបញ្ចាំងពីអតិរេកផលិតកម្មអង្ករទេ ។ តាមទិន្នន័យនេះ កម្ពុជាបាននាំចេញអង្ករ ៤៥0តោន នៅឆ្នាំ២000 ប្រហែល ១៥.000តោន/ឆ្នាំ នៅឆ្នាំ២០០១-0២ និង ៤.៩៥0តោន/ឆ្នាំ នៅឆ្នាំ ២00៣-0៨ (តារាង ២) ។ តួលេខនេះបង្ហាញថា គិតជាមធ្យមមានតែ ១% នៃអតិរេកស្រូវប៉ុណ្ណោះ ដែលគេបាននាំចេញជាអង្ករ នៅចន្លោះឆ្នាំ ២000 និង ២00៨ ។ ក្នុងការសិក្សាខ្លះ គេបានកត់ត្រាថា អតិរេកស្រូវមួយភាគធំ ត្រូវបានដឹកជញ្ជូនជាលក្ខណៈមិនផ្លូវការទៅកាន់ប្រទេសថៃ និងវៀតណាម ដើម្បីកិនជាអង្ករសំរាប់នាំចេញដោយប្រទេសទាំងនោះ (Hing et al. 2007, Sin 2009) ។

ធនាគារពិភពលោក (២00៣) បានរាយការណ៍ថា ក្នុងឆ្នាំ ២00១ កម្ពុជានាំចេញអង្ករប្រហែល ៦0.000តោន គឺច្រើនជាងតួលេខផ្លូវការ ៤ដង ។ នៅឆ្នាំដដែលនោះ ស្រូវ ៤៥0.000តោន ដែលមានតម្លៃ ៦៩,៧លានដុល្លារ (ប្រសិនបើធ្វើការជួញដូរតាមច្រកផ្លូវការ) ត្រូវបានដឹកជញ្ជូនជាលក្ខណៈមិនផ្លូវការទៅប្រទេសថៃ នឹងវៀតណាម (World Bank 2003) ។ តួលេខបូកចូលគ្នានៃអង្ករ និងស្រូវ បាននាំចេញទាំងនោះ វាស្មើនឹង ៦៧% នៃអតិរេកស្រូវ (៨១២.000តោន) ក្នុងឆ្នាំនោះ ដូច្នេះ មានអតិរេកស្រូវ ៣៣% ទៀត ដែលនៅសល់ក្នុងប្រទេស ។[២]

## សមត្ថភាពកិនស្រូវ

សមត្ថភាពកិនស្រូវ ជាបញ្ហាប្រឈមសំខាន់មួយ ចំពោះដំណើរការផលិតអង្ករនៅកម្ពុជា ។ ក្នុងមួយឆ្នាំ កម្ពុជាអាចផលិតស្រូវបាន ៤,១២លានតោន ប៉ុន្តែធនាគារពិភពលោក (២00៣) ប៉ាន់ស្មានថា កម្ពុជាមានសមត្ថភាពកិនស្រូវត្រឹមតែ ១,៣១លានតោនប៉ុណ្ណោះ ដូច្នេះ មានស្រូវ ២,៨១លានតោនទៀត ដែលកម្ពុជាមិនអាចកិនបាន ។ តួលេខនេះបង្ហាញថា កម្ពុជាត្រូវបង្កើនសមត្ថភាពកិនស្រូវយ៉ាងហោចណាស់ចំនួន ៣ដងថែមទៀត ដើម្បីបំពេញតម្រូវការក្នុងស្រុក ក្នុងឆ្នាំ២00៨ (តារាង ៣) ។

ដំណើការកែច្នៃអង្ករ ប្រឈមមុខនឹងឧបសគ្គមួយចំនួន ។ ទីមួយ រោងចក្រកិនស្រូវមួយចំនួនធំ ពឹងផ្អែកលើម៉ាស៊ីនចាស់ៗ ដែលធ្វើឲ្យគ្រាប់អង្ករបាក់អស់យ៉ាងច្រើន ហើយតម្លៃអង្ករក៏ថយចុះ ។ អង្ករកម្ពុជា មានគ្រាប់អង្ករបាក់អស់ ៣៥% ហើយត្រូវបានចាត់ទុកជាអង្ករធុនអន់ បើធៀបនឹងអង្ករថៃប្រភេទគ្រាប់វែង ឬអង្ករវៀតណាម ដែលមានគ្រាប់បាក់ តិចជាង ៥% ។ គ្រាប់ពូជច្រើនប្រភេទលាយឡំគ្នា (ពូជមិនសុទ្ធ) និងការចាត់ចែងទុកដាក់មិនសូវល្អក្រោយពេលប្រមូលផល ក៏បង្កើនភាគរយអង្ករបាក់ដែរ ។ ទីពីរ បន្ទុកចំណាយខ្ពស់លើឥណទាន និងកង្វះទុនបង្វិល បានកាត់បន្ថយលទ្ធភាពម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្នុងការទិញស្រូវពីកសិករ និងកែលំអគ្រឿងម៉ាស៊ីន ។ ប្រធានសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា បញ្ជាក់ថា ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ត្រូវការកំចីជាង ៣៧៥លានដុល្លារ សំរាប់ទិញអតិរេកស្រូវនៅរដូវស្រូវជន់ (The Economy Today 2008) ។ មកទល់ពេលនេះ សមាគមទទួលបានកំចីតិចតួចប៉ុណ្ណោះ ពីរដ្ឋាភិបាល ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ទីបី ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ខ្វះខាតលទ្ធភាពចូលទៅទីផ្សារអន្តរជាតិ ពីព្រោះពុំមានលទ្ធភាពផលិតអង្ករគុណភាពល្អ ឲ្យបានច្រើនជាទៀងទាត់បាន ។

## កត្តាកំណត់ផលិតភាពស្រូវ

ដូចមានបញ្ជាក់ក្នុងផ្នែកទី២ ផលិតភាពស្រូវនៅកម្ពុជា ស្ថិតក្នុងកំរិតទាបជាងគេបំផុតនៅក្នុងតំបន់ ។ ការសិក្សាមុនៗ (e.g. World Bank 2006; Markussen 2008) បង្ហាញថា កម្មសិទ្ធិដីមានសុវត្ថិភាព តែងជះឥទ្ធិពលជាវិជ្ជមានទៅលើផលិតភាពកសិកម្ម ។ ផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២00៤ ធនាគារពិភពលោក (២00៦) រកឃើញថា កម្មសិទ្ធិដីធ្លីក្នុងទំរង់ជាលិខិតបញ្ជាក់ការកាន់កាប់ បង្កាន់ដៃទទួលពាក្យសុំកម្មសិទ្ធិ ឬឯកសារផ្លូវការផ្សេងទៀត ធ្វើឲ្យទិន្នផលដំណាំ កើន ៦៥% ។ ដោយប្រើប្រាស់ទិន្នន័យដដែលនេះ Markussen (២00៨) បាន

២ បើគិតតាមអត្រាបំប្លែង 0,៦៣ នោះ មានអង្ករប្រហែល ៦0.000តោន ត្រូវបានកិនយកពីស្រូវ ។ អត្រាបំប្លែង ប្រែប្រួលទៅតាមទំហំនៃរោងម៉ាស៊ីនកិនស្រូវ ។ សំរាប់រោងម៉ាស៊ីនធ្វើអាជីវកម្មកិនស្រូវខ្នាតតូច អត្រាបំប្លែងទំនងជាតិចជាង 0,៥៥ (World Bank 2003) ។

តារាង ៣: សមត្ថភាពកិនស្រូវ

| | ផលិតកម្មស្រូវ (ពាន់តោន) | សមត្ថភាពកិនស្រូវសរុប (ពាន់តោន) | ឱនភាពសមត្ថភាពកិនស្រូវ(ពាន់តោន) | ការប្រើប្រាស់ក្នុងស្រុក (ពាន់តោន) | សមត្ថភាពកិនស្រូវសរុប/ការប្រើប្រាស់ក្នុងស្រុក | កំហាតបង់នៃប្រាក់ចំណូលពីការនាំចេញ (លានដុល្លារ) |
|---|---|---|---|---|---|---|
| ធនាគារពិភពលោក (2003) | 4120 | 1310 | 2810 | | | |
| 2008 សេណារីយ៉ូ 1 | 7150 | 1310 | 5840 | 3327 | 0.39 | 1519 |
| 2008 សេណារីយ៉ូ 2 | 7150 | 2620 | 4530 | 3327 | 0.79 | 1178 |
| 2008 សេណារីយ៉ូ 3 | 7150 | 3930 | 3220 | 3327 | 1.18 | 838 |

*ប្រភព: WB(2003), IS(2008), និង ការប៉ាន់ស្មានរបស់អ្នកនិពន្ធ*

រកឃើញលទ្ធផលស្រាវជ្រាវស្របគ្នា បើទោះជាកំណើនផលិតភាពនៅក្នុងការស្រាវជ្រាវរបស់គាត់ បានត្រឹមតែពាក់កណ្តាលនៃតួលេខដែលធនាគារពិភពលោកបានរកឃើញក្តី ។ ទោះបីមានការទទួលស្គាល់ជាទូទៅថា កម្មសិទ្ធិដីមានការផលប៉ះពាល់ល្អលើផលិតភាពកសិកម្មក្តី ក៏មិនទាន់មានកំណត់អ្វីឲ្យជាក់លាក់ពីឥទ្ធិពលទៅលើផលិតកម្មស្រូវទេ ។ លោក គុង គឹមស៊ិន (ឯកសារចេញផ្សាយឆាប់ៗ) ព្យាយាមបំពេញចន្លោះប្រហោងនេះ ដោយប្រើប្រាស់ CSES 2007 ហើយកត់សម្គាល់ថា ការដាំដុះលើដីដែលបានចុះបញ្ជីមានក្រដាសស្នាមត្រឹមត្រូវ ផ្តល់ផលជាមធ្យមច្រើនជាងការដាំដុះលើដីដទៃទៀត ២០% ។ ម៉្យាងវិញទៀត ការសិក្សារបស់លោក គុង គឹមស៊ិន បញ្ជាក់ថា ធាតុចូលផ្សេងទៀតមានដូចជា គ្រាប់ពូជ ជី ថ្នាំសំលាប់សត្វល្អិត ជីលាមកសត្វ និងជីកំប៉ុស អគ្គិសនីសំរាប់បំរើការដាំដុះ ការដឹកជញ្ជូនធាតុចូលជាសំភារៈ ពលកម្មស៊ីឈ្នួល ការស្រោចស្រព និងបរិក្ខារកសិកម្មទំនើបៗមានដូចជា ត្រាក់ទ័រ គោយន្ត និងម៉ាស៊ីនបូមទឹកជាដើម សុទ្ធតែបានជួយចូលរួមចំណែកជាវិជ្ជមានក្នុងផលិតកម្មស្រូវ ។ លទ្ធផលស្រាវជ្រាវគួរចាប់អារម្មណ៍ផ្សេងៗទៀត គឺការដាំដុះលើផ្ទៃដីតូច តែងតែមានប្រសិទ្ធភាពជាងលើផ្ទៃដីធំ គម្រោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល គេសង្កេតឃើញថាពុំមានឥទ្ធិពលវិជ្ជមានទេ ប៉ុន្តែគម្រោងសហការគ្នារវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបានជួយបង្កើនផលិតភាពកសិកម្ម ។ គ្រោះរាំងស្ងួត មានផលប៉ះពាល់ជាអវិជ្ជមាន រយៈពេលវែងលើផលិតកម្មស្រូវ តួយ៉ាង គ្រោះរាំងស្ងួតនៅក្នុងរដូវនេះ នឹងប៉ះពាល់ដល់ផលិតភាពកសិកម្មនៅរដូវក្រោយ ។

### យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល

រដ្ឋាភិបាល បានផ្តល់អាទិភាពដល់ការជំរុញកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើចំរុះកម្ម និងការលើកកំពស់កសិ-ឧស្សាហកម្ម ។ ប៉ុន្តែរដ្ឋាភិបាលបានបង្វែរចំណាប់អារម្មណ៍ពីការពង្រីកផ្ទៃដីដាំដុះ មកជំរុញការដាំដុះបែបអតិផលលើផ្ទៃដីមានស្រាប់វិញ (តារាង ៤) ។ ចំណែកវិស័យកសិកម្មក្នុងថវិកាជាតិ មានកម្រិត ២% ជាមធ្យម សំរាប់ឆ្នាំ ២០០៨-១៣ ឬ ០,២% ឯកតាភាគរយ (0.2 percentage point) ទាបជាងក្នុង ឆ្នាំ១៩៩៩-២០០៧ (RGC 2009) ។ ជាទូទៅ ការបែងចែកថវិកាសំរាប់វិស័យកសិកម្មគ្មានការប្រែប្រួលជាដុំកំភួនទេ ក្នុងទសវត្សរ៍មុននេះ ។

តាំងពីបានចូលជាសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកមក កម្ពុជាបានធ្វើសេរីភាវូបនីយកម្មគោលនយោបាយសំរាប់ការនាំចេញផលិតផលកសិកម្ម ។ មួយវិញទៀត គំនិតផ្តួចផ្តើមបើកចំហពាណិជ្ជកម្មគ្រប់យ៉ាងក្រៅពីអាវុធ ដែលបានធ្វើឡើងក្នុងឆ្នាំ២០០១ ដោយសហភាពអឺរ៉ុប មានសារៈសំខាន់សំរាប់បើកផ្លូវឲ្យដល់ការនាំចេញអង្ករពីកម្ពុជា ទៅកាន់ទីផ្សារសហភាពអឺរ៉ុប ។ គំនិតផ្តួចផ្តើមនេះ អនុញ្ញាតឲ្យមានការនាំចូលទំនិញដោយគ្មានជាប់ពន្ធគយ និងកូតា (លើកលែងតែអាវុធចេញ) ពីបណ្តាប្រទេសអភិវឌ្ឍន៍តិច ។

### ផលប៉ះពាល់ខាងគោលនយោបាយ

ទោះបីផលិតភាពស្រូវកម្ពុជា នៅទាបជាងប្រទេសជិតខាងក្តី ប៉ុន្តែផលិតកម្មស្រូវសរុបរបស់កម្ពុជា មានច្រើនលើសតម្រូវការក្នុងស្រុក និងមានអតិរេកសំរាប់ការនាំចេញទៀតផង ។ ដោយសារសមត្ថភាពកិនស្រូវរបស់កម្ពុជា នៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការ ដូច្នេះ

តារាង ៤: សូចនាករសំខាន់ៗសំរាប់ដំណាំស្រូវ

| សូចនាករសំខាន់ៗ | ឯកតា | 2008 តួលេខពិត | 2009 ប៉ាន់ស្មាន | 2010 ព្យាករណ៍ | 2011 ព្យាករណ៍ | 2012 ព្យាករណ៍ | 2013 ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ដីកំពុងដាំដុះ | ពាន់ហិកតា | 596 | 750 | 950 | 1000 | 1000 | 1000 |
| ស្រូវ៖ ផ្ទៃដីដាំដុះ | លានហិកតា | 2.61 | 2.63 | 2.65 | 2.65 | 2.65 | 2.65 |
| ទិន្នផលក្នុង១ហិកតា | តោន | 2.74 | 2.77 | 2.80 | 2.83 | 2.87 | 3.00 |
| ផលិតកម្មស្រូវ | លានតោន | 7.17 | 7.28 | 7.42 | 7.50 | 7.6 | 7.95 |
| ផ្ទៃដីស្រោចស្រព | ពាន់តោន | 827 | 867 | - | - | - | - |

*ប្រភព: RGC (2009)*

អតិរេកស្រូវភាគច្រើន ក៏ត្រូវបាននាំចេញជាលក្ខណៈក្រៅផ្លូវការទៅប្រទេសថៃ និងវៀតណាម ដើម្បីកិនជាអង្ករ និងនាំចេញបន្តទៀត ។ យោងតាមសក្តានុពលនៃផលិតកម្មស្រូវ កំណើនតំលៃបន្ថែមលើផលស្រូវមានសារៈសំខាន់ណាស់ សម្រាប់កំណើនវិស័យកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ ។

គោលនយោបាយរាជរដ្ឋាភិបាល សម្រាប់ឆ្នាំ២០០៩-១៣ មានគោលដៅសម្រេចឲ្យបានកំណើនខ្ពស់ និងមានចីរភាពនៃដំណាំស្រូវ តាមរយៈការបន្តចេញប័ណ្ណកម្មសិទ្ធិដី ជាពិសេសដល់ប្រជាកសិករ ការបង្កើនលទ្ធភាពស្រោចស្រព ការកែលំអប្រព័ន្ធគ្រប់គ្រងទឹកសំរាប់កសិកម្ម ការលើកទឹកចិត្តកសិករឲ្យប្រើបច្ចេកវិទ្យាកសិកម្មថ្មី ការបង្កើនសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ការប្រើដីស្រែឲ្យមានប្រសិទ្ធិភាពខ្ពស់ និងការពន្លឿនការផ្តល់សម្បទានដីដល់កសិករដែលមានដីតិច ។

*លោកឧកញ៉ា ភួ ពុយ បានអំពាវនាវឲ្យមានកិច្ចប្រឹងប្រែងរួមគ្នាជួយដោះស្រាយឧបសគ្គនានា ដើម្បីសំរេចបាននូវសក្តានុពលនៃការនាំចេញអង្ករ៖*

មានសកម្មភាពជាច្រើនត្រូវធ្វើឡើង ដើម្បីកែលំអផលិតកម្ម ការកែច្នៃ និងការនាំចេញអង្ករ ។ សំរាប់ផលិតកម្មគេត្រូវ៖ (១) បង្កើនការផ្គត់ផ្គង់ស្រូវពូជ (មានទាំងកន្លែងផលិតស្រូវពូជផង) ដោយតម្រូវតាមទីផ្សារនាំចេញ (២) កែលំអបច្ចេកទេសផលិតកម្ម និងគ្រប់គ្រង (៣) កែលំអបច្ចេកទេសប្រមូលផល (៤) បង្កើតតំបន់មានសក្តានុពលខ្ពស់ ដែលអាចដាំស្រូវបានពីរដងក្នុងមួយឆ្នាំ (៥) ដាក់អនុវត្តក្របខ័ណ្ឌមួយសំរាប់ការធានាគុណភាព (៦) ត្រូវមានគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ជួយគាំទ្រដល់ការដាំដុះបែបពាណិជ្ជកម្ម (៧) ផ្តល់ឥណទានមានការប្រាក់ទាបសមរម្យ សំរាប់រយៈពេលខ្លី មធ្យម និងវែង តាមរយៈស្ថាប័នដែលធ្វើការជិតស្និទ្ធជាមួយកសិករ និងសហគមន៍ ។

ការជំរុញ និងអភិវឌ្ឍន៍ការកែច្នៃ និងវិចខ្ចប់អង្ករ គួរប្រើប្រាស់បរិក្ខារទំនើបៗ និងអនុវត្តតាមស្តង់ដារទីផ្សារអន្តរជាតិ ។ ការងារនេះក៏ត្រូវមានឥណទានមានតម្លៃថោកសមរម្យ សំរាប់ធ្វើវិនិយោគក្នុងរយៈពេលខ្លី មធ្យម និងវែង ។ ទំហំឥណទាន គួរបត់បែនទៅតាមតម្រូវការជាក់ស្តែងរបស់សហគ្រាស ។ រដ្ឋាភិបាលត្រូវចេញមុខធានាដើម្បីឲ្យស្ថាប័នហិរញ្ញវត្ថុ និងធនាគារ ព្រមផ្តល់កំចីទៅឲ្យវិស័យឯកជន ។ មួយវិញទៀត អគ្គិសនី ជាកត្តាសំខាន់បំផុតមួយសំរាប់ការកែច្នៃអង្ករ (និងផលិតផលជាច្រើនទៀត) ។ គួរដាក់អនុវត្តថ្លៃអគ្គិសនី (ទាប) ពិសេសមួយសំរាប់សហគ្រាសកែច្នៃ និងវិចខ្ចប់អង្ករ យ៉ាងហោចណាស់នៅថ្ងៃចុងសប្តាហ៍ ឬនៅពេលយប់ជ្រៅ ។ មធ្យោបាយមួយ សម្រាប់បង្កើនការផ្គត់ផ្គង់អគ្គិសនីតំលៃថោក គឺការអនុញ្ញាតឲ្យវិនិយោគិនធំៗ ផលិតថាមពលអគ្គិសនីដោយខ្លួនឯង ហើយលក់អតិរេកអគ្គិសនីរបស់គេទៅតំបន់ជិតខាងនោះ ។

រដ្ឋាភិបាល គួរជួយស្វែងរកទីផ្សារសំរាប់នាំចេញអង្ករនៅតាមប្រទេស ដូចជា ហ្វីលីពីន ឥណ្ឌូនេស៊ី និងតំបន់អឺរ៉ុប ជាដើម ។ ក្របខ័ណ្ឌច្បាប់ទាក់ទងនឹង កសិកម្ម កសិឧស្សាហកម្ម និងពាណិជ្ជកម្ម ក៏គួរពង្រឹងឡើងដែរ ។ គួរមានច្បាប់តឹងរឹង និងការពង្រឹងអនុវត្តច្បាប់ ស្តីពីការនាំចេញ និងការនាំចូល ។ ការនាំចេញ និងនាំចូលផលិតផលជាក់លាក់មួយចំនួន គួររឹតបន្តឹង ឬហាមឃាត់ ហើយចំពោះផលិតផលឯទៀតគួរបើកទូលាយ ។ សេវាទ្រទ្រង់ពាណិជ្ជកម្មគួរកែលំអថែមទៀត គឺមានដូចជា ការលើកលែងពន្ធ ការកាត់បន្ថយការងារក្រដាសស្នាម ការកាត់បន្ថយចំណាយដឹកជញ្ជូនទាំងតាមផ្លូវគោក និងផ្លូវសមុទ្រ និងការកែលំអសេវាកំពង់ផែ ។ ដើម្បីឲ្យវិស័យឯកជន និងរដ្ឋាភិបាល អនុវត្តបានជោគជ័យនូវសេដ្ឋកិច្ចទីផ្សារសេរី គេត្រូវធ្វើការគណនាជានិច្ច ពីផលចំណេញ និងបន្ទុកចំណាយ ។ គោលការណ៍នេះ អនុវត្តលើគ្រប់វិស័យពាក់ព័ន្ធទាំងអស់ ជាពិសេសកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ។

## ឯកសារយោង


The Economy Today (2008), Gold is Money: Cambodian Savings Bank, Volume 2, Number 10, March 1-15 (Phnom Penh: Cambodia)

Hang Chuon Naron (2010), Macroeconomic Development in 2009, Presentation at Cambodian Economic Association Annual Meeting

Hing Vutha, Chan Sophal, and Sok Sina (2007), "Cambodia's Agricultural Production and Trade", Cambodian Economic Review, Cambodian Economic Association (Phnom Penh: Cambodia)

Hossein Jalilian and Glenda Reyes (2010), The Global Financial Crisis Discussion Series, Paper 12: Cambodia Phase 2 (London: ODI)

Markussen Thomas (2008), "Property Rights, Productivity, and Common Property Resources: Insights from Rural Cambodia", World Development, Vol.36, No.11, pp.2277-2296

Ministry of Agriculture, Forestry, and Fisheries (2009), Annual Report for Agriculture Forestry and Fisheries 2008-2009 (Phnom Penh: Cambodia)

National Institute of Statistics (2006, 2007), National Accounts of Cambodia, Ministry of Planning (Phnom Penh: Cambodia)

National Institute of Statistics (2008), Statistical Yearbook of Cambodia, Ministry of Planning (Phnom Penh: Cambodia)

Sin Meng Srun (2009), Rice for Economic Growth and Food Security (memo), Economic, Social and Cultural Council (ECOSOCC) (Phnom Penh: Cambodia)

Yu Bingxin and Fan Shenggen Fan (2009), Rice Production Responses in Cambodia, IFPRI Discussion Paper

Royal Government of Cambodia (2009), National Strategic Development Plan Update 2009-2013, (Phnom Penh: Cambodia)

The World Bank (2003), Towards a Private Sector-led Growth Strategy for Cambodia Volume 1: Value Chain Analysis, East Asia and Pacific Region

The World Bank (2006), Cambodia-Halving Poverty by 2015: Poverty Assessment 2006, East Asia and Pacific Region

Tong Kimsun (forthcoming), Land Tenure and Paddy Productivity: Evidence from Cambodia, Cambodia Development Resource Institute (Phnom Penh: Cambodia)

# ការពង្រឹងវិស័យសំខាន់ៗ ដើម្បីសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា៖ ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល

ប្រទេសកម្ពុជាមួយផ្នែកដោយសារហេតុការណ៍ក្នុងប្រវត្តិសាស្ត្រដែលគេអាចយល់បាននោះផង បានទទួលរងគ្រោះយ៉ាងខ្លាំងពីកង្វះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក និងថាមពល ។ ដើម្បីអាចឈានដល់កំណើនខ្ពស់ប្រកបដោយចីរភាព គេត្រូវដោះស្រាយឲ្យបានសក្តិសិទ្ធិ នូវកង្វះខាត និងកត្តារាំងស្ទះផ្សេងៗ ដែលកម្ពុជាកំពុងជួបប្រទះក្នុងវិស័យនេះ ។ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ត្រូវបានកែលំអបានច្រើនហើយក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក្តី ប៉ុន្តែវិស័យនេះ នៅមានកំហិតច្រើនសន្ធឹកទៀត ដែលធ្វើឱ្យផលិតករនៅកម្ពុជា ត្រូវចាញ់ប្រៀបគេក្នុងការប្រកួតប្រជែង ហើយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចជាទូទៅនៅកម្ពុជា ក៏ជួបឧបសគ្គធំធេង ។ អត្ថបទនៅខាងក្រោមនេះ ជាសេចក្តីសង្ខេបលើបទបង្ហាញរបស់ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន[១] ឯកឧត្តម ហាវ រតនៈ[២] និងលោក David Kerr[៣] ដែលបានពិភាក្សាវែកញែកពីស្ថានភាពសារៈសំខាន់ និងការរំពឹងទុក ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

បណ្ឌិត ណារ៉ុន បានពិនិត្យពីតួនាទីហេដ្ឋារចនាសម្ព័ន្ធក្នុងន័យទូលំទូលាយនៃការចូលរួមចំណែកក្នុងវិបុលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា ដោយបានញែកចេញពីគ្នានូវហេដ្ឋារចនាសម្ព័ន្ធប្រភេទខុសៗគ្នា និងធ្វើការថ្លឹងថ្លែងពិចារណាក្នុងបរិបទនៃគោលការណ៍ខាងភូមិសាស្ត្រនយោបាយដ៏ចាំបាច់ សំរាប់កំណើនរយៈពេលវែង ។

លោកបណ្ឌិត បានលើកពីហេដ្ឋារចនាសម្ព័ន្ធពីរប្រភេទធំៗគឺ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ក្របខ័ណ្ឌច្បាប់ (hard and soft infrastructure) ដោយចង្អុលបង្ហាញថា ជាលក្ខណៈប្រវត្តិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ បានល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ ឧទាហរណ៍ ក្នុងការស្តារជួសជុលផ្លូវថ្នល់ មានផ្លូវថ្នល់ប្រវែង ៥៥០គីឡូម៉ែត្រ ត្រូវបានស្តារឡើងនៅអំឡុងឆ្នាំ១៩៩៣-១៩៩៧ ផ្លូវថ្នល់ប្រវែង ២៣៥០គីឡូម៉ែត្រ នៅអំឡុងឆ្នាំ១៩៩៨-២០០៣ និង ៦០០គីឡូម៉ែត្រ នៅអំឡុងឆ្នាំ២០០៤-២០០៧ ។ ក្នុងពេលថ្មីៗនេះ ទូរគមនាគមន៍ ជាពិសេសទូរស័ព្ទចល័ត និងការប្រើប្រាស់អ៊ីនថឺណិត បានកើនឡើងប្រមាណ ៥០%ក្នុងមួយឆ្នាំ ។ លោកបានវែកញែកទៀតថា កម្ពុជាបានស្តារ និងកសាងឡើងវិញយ៉ាងច្រើននូវបណ្តាញដឹកជញ្ជូន ដូចជា ផ្លូវថ្នល់ ផ្លូវទឹក ផ្លូវដែក និងអាកាសយានដ្ឋាន ។

ផ្លូវដែកនៅកម្ពុជា រំពឹងថា នឹងមានការកែលំអគួរឲ្យកត់សម្គាល់ ។ នៅខែមីនា ២០០៧ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី លើគំរោងស្តារផ្លូវដែកនៅកម្ពុជា ដែលមានទឹកប្រាក់ចំនួន ៧៣លានដុល្លារអាមេរិក ដោយក្នុងនោះ ភាគីកម្ពុជាត្រូវចូលរួមវិភាគទាន ១៥លានដុល្លារអាមេរិក ។ គំរោងនេះ រួមមានការសាងសង់ផ្លូវដែកប្រវែង ២៥៧គីឡូម៉ែត្រ ពីភ្នំពេញទៅ Loc Ninh ។ រាជរដ្ឋាភិបាល ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្បទានមានរយៈពេល ៣០ឆ្នាំ ជាមួយក្រុមហ៊ុនអូស្ត្រាលី Toll Holdings លើការធ្វើប្រតិបត្តិការផ្លូវដែក ក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិរវាងរដ្ឋ និងឯកជន និងចុះហត្ថលេខាជាមួយក្រុមហ៊ុនបារាំង TSO លើការស្តារផ្លូវដែកឡើងវិញ ។

ទាក់ទិននឹងក្របខ័ណ្ឌច្បាប់ បណ្ឌិត ណារ៉ុន បានវិភាគគាំទ្រដល់កិច្ចការពារកម្មសិទ្ធិបញ្ញា ការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ ការិយាល័យច្រកចេញចូលតែមួយ សំរាប់ជួយសំរួលកាត់បន្ថយរយៈពេលផ្តល់ការអនុម័តយល់ព្រម និងចំណាយប្រតិបត្តិការ ព្រមទាំងការកែលំអបរិយាកាសពាណិជ្ជកម្ម តាមរយៈកំណែទម្រង់អភិបាលកិច្ចផ្សេងៗ ។ ការសំរបសំរួលពាណិជ្ជកម្ម ក៏ដូចជាការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងធានារ៉ាប់រង ក៏ត្រូវមានអាទិភាពខ្ពស់ដែរ ។

ក្នុងការប្រមើលមើលពី វិស័យហេដ្ឋារចនាសម្ព័ន្ធ បណ្ឌិត ណារ៉ុន បានពិភាក្សាលើប្រធានបទទាក់ទងនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងតួនាទីរបស់វាក្នុងការសំរេចបានគោលដៅអភិវឌ្ឍន៍របស់កម្ពុជា ។ គោលនយោបាយនេះមានសមាសធាតុសំខាន់ៗដូចតទៅ៖

- ការស្តារជួសជុល និងសាងសង់ ផ្លូវជាតិនិងផ្លូវខេត្ត ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ និងប្រព័ន្ធធារាសាស្ត្រ
- ទូរគមនាគមន៍អេឡិចត្រូនិក ផលិតកម្មនិងបណ្តាញចែកចាយអគ្គិសនី
- ការទាក់ទាញវិស័យឯកជនឲ្យធ្វើវិនិយោគ លើការងារសាធារណៈ (BOT-សាងសង់-អាជីវកម្ម-ផ្ទេរ) ក្នុងក្របខ័ណ្ឌជាសម្បទាន ។

១ រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានអចិន្ត្រៃយ៍ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI ។

២ អនុប្រធាននាយកដ្ឋានថវិកា មន្ត្រីត្រួតពិនិត្យរដ្ឋអមអគ្គិសនីកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

៣ អគ្គនាយកក្រុមហ៊ុន Toll កម្ពុជា ។

ការស្ដារជួសជុល និងកែលំអហេដ្ឋារចនាសម្ព័ន្ធ មានគោលដៅចំបង ជួយសំរួលដល់របៀងកំណើននៅកម្ពុជា និងមានជាអាទិ៍ តភ្ជាប់ប៉ូលកំណើននានានៅកម្ពុជា ហើយក្នុងពេលជាមួយគ្នា ធ្វើការកែលម្អ និងដំណើរការឲ្យបានជាក់ស្ដែង នូវរបៀងសេដ្ឋកិច្ចមេគង្គ-តណ្ហ ដើម្បីជួយសំរួលដល់ពាណិជ្ជកម្មក្នុងតំបន់ ។

ទាក់ទងនឹងកំណើន គោលដៅចំបងគឺ ត្រូវជំរុញកំណើនតំបន់ភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ ។ ក្រុងភ្នំពេញ ដើរតួនាទីសំខាន់ក្នុងផលិតកម្មកាត់ដេរ និងការនាំចេញ ខេត្តសៀមរាបក្នុងវិស័យទេសចរណ៍វប្បធម៌ និងក្រុងព្រះសីហនុក្នុងវិស័យទេសចរណ៍តំបន់ឆ្នេរ និងផលិតកម្មប្រេងកាត ។ ខេត្តបាត់ដំបង ជាប៉ូលកំណើនមួយទៀត ដែលមានសារៈសំខាន់សំរាប់ផលិតកម្មកសិកម្ម និងពាណិជ្ជកម្ម ។

នៅក្នុងបរិបទនៃរបៀងសេដ្ឋកិច្ចមេគង្គ-តណ្ហ គោលដៅធំមួយគឺ ការតភ្ជាប់ប្រទេស កម្ពុជា មីយ៉ាន់ម៉ា ថៃ និងវៀតណាម ជាមួយប្រទេសតណ្ហ ដោយឆ្លងកាត់តាមតំបន់ឆ្នេរប៉ែកខាងកើតរបស់កម្ពុជា ក្នុងនេះមានទាំង ក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រជ្រៅនៅកម្ពុជា ។ នាបច្ចុប្បន្ន ផ្លូវដែកតភ្ជាប់ក្រុងព្រះសីហនុ និងក្រុងភ្នំពេញ កំពុងតែកែលំអថែមទៀត ។ នៅក្រុងព្រះសីហនុ មានផែនការបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs) ច្រើនណាស់ និងគំរោងវិនិយោគខាងឧស្សាហកម្មមួយចំនួន ។ ទីនេះជាតំបន់គោលដៅទេសចរណ៍កំពុងឈានឡើង និងស្ថិតនៅជិតតំបន់ផលិតប្រេងកាត និងឧស្ម័ន ។ ខេត្តសំខាន់មួយទៀត គឺបាត់ដំបង ដែលជាចំណុចស្នូលនៃតំបន់កសិកម្មរបស់កម្ពុជា ដោយមានផលិតកម្មខ្នាតធំនូវស្រូវ ដំឡូងឈើ និងពោត ។ លក្ខណៈសំគាល់ផ្សេងៗទៀតនៃខេត្តនេះ គឺការប្រមូលផ្តុំប្រជាជនច្រើនៗ តួនាទីជាមជ្ឈមណ្ឌលសេវាកសិកម្ម និងពាណិជ្ជកម្មដ៏សំខាន់ និងជាច្រកតភ្ជាប់ទំនាក់ទំនងយ៉ាងល្អរវាងក្រុងភ្នំពេញ និងប្រទេសថៃ ។ ស្វាយរៀង-បាវិត ជាតំបន់សំខាន់មួយទៀត ដោយសារនៅជិតកញ្ចុំឧស្សាហកម្មនៃទីក្រុងហូជីមិញ ទីក្រុងដុងណៃ ជាដើម ។ តំបន់នេះ ក៏មានសក្ដានុពលក្លាយទៅជាមជ្ឈមណ្ឌលសេវាកម្មដ៏សំខាន់ ដោយសារការរំពឹងទុកពីពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ជាមួយកញ្ចុំឧស្សាហកម្មនៅក្នុង និងនៅជុំវិញទីក្រុងហូជីមិញ ។ វិនិយោគឧស្សាហកម្ម និង SEZs មួយចំនួន ត្រូវបានគ្រោងឡើងសំរាប់តំបន់នេះ ដែលមានក្បាលដីធំៗសមស្របសំរាប់ការពង្រីកឧស្សាហកម្ម ។ សេរីសោភ័ណ-ប៉ោយប៉ែត ក៏ជាតំបន់សំខាន់មួយផ្នែកដែរ ដោយសារនៅជិតកញ្ចុំឧស្សាហកម្មក្រុងបាងកក តំបន់ឆ្នេរខាងកើត និង Chachoengsao-Prachinburi ដែលកំពុងផុសឡើង (២៥០គីឡូម៉ែត្រ) ។ តំបន់នេះមានសក្ដានុពលក្លាយទៅជាមជ្ឈមណ្ឌលសេវាកម្មដ៏សំខាន់ ដោយសារការរំពឹងទុកពីពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ជាមួយកញ្ចុំឧស្សាហកម្មនៅក្នុង និងនៅជុំវិញក្រុងបាងកក និងតំបន់ឆ្នេរខាងកើត ។ ប្រជាជនដ៏ច្រើននៅខេត្តជិតខាង គឺជាប្រភពពលកម្មមួយយ៉ាងធំ ។ ការអភិវឌ្ឍផ្លូវថ្នល់ និងផ្លូវដែកតភ្ជាប់សេរីសោភ័ណ-ប៉ោយប៉ែត និងក្រុងភ្នំពេញ ក៏ដូចជាក្រុងបាងកក ក៏មានក្នុងគំរោងដែរ ។

លោក រតនៈ បានធ្វើបទបង្ហាញ ដែលផ្ដោតលើការវិភាគពីវិស័យថាមពលនៅកម្ពុជា និងជាពិសេសអគ្គិសនីកម្ពុជា (EDC) ។ ចំពោះផលិតកម្ម និងថាមពលដែលមានសំរាប់ផ្គត់ផ្គង់នៅក្នុងប្រទេស ការកែលំអគួរកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗ ដូចមានបង្ហាញក្នុងតារាង ១ អាចអនុវត្តទៅបាន ដោយសារការបង្កើនផលិតកម្មក្នុងប្រទេស គួបផ្សំនឹងការនាំចូលអគ្គិសនីពីប្រទេសជិតខាង ។ ទិន្នន័យ (មិនបានបង្ហាញក្នុងអត្ថបទនេះទេ) បានបញ្ជាក់ដែរថា ប្រសិទ្ធភាព EDC បានកើនឡើង ពោលគឺ កំហាតប្រតិបត្តិការបានថយចុះបន្តិចក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។

**តារាង ១: ផលិតកម្ម** EDC

| ផលិតកម្ម | ឯកតា | 2007 | 2008 | 2009 |
|---|---|---|---|---|
| សមត្ថភាពដាក់ដំឡើង | MW | 386 | 408 | 516 |
| សមត្ថភាពប្រើការបាន | MW | 356 | 373 | 473 |
| ផលិតកម្មសរុប | GWh | 1,423 | 1,622 | 1,818 |
| *ផលិតកម្មរបស់ EDC* | GWh | 294 | 163 | 100 |
| *ផលិតកម្មរបស់ IPP* | GWh | 1060 | 1190 | 1,013 |
| *ការនាំចូល* | GWh | 69 | 269 | 705 |
| ផលិតកម្មដោយ DO | GWh | 105 | 93 | 30 |
| ផលិតកម្មដោយ HFO | GWh | 1,200 | 1,190 | 1,001 |
| ផលិតកម្មដោយវារី | GWh | 49 | 47 | 47 |
| ផលិតកម្មដោយធ្យូងថ្ម | GWh | - | 23 | 34 |

តារាង ២: មូលដ្ឋានអតិថិជនរបស់ EDC

| | 2000 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|
| និវាសជន | | 199,478 | 242,835 | 262,361 | 287,266 | 306,898 |
| ជនបរទេស | | 1,802 | 1,903 | 2,078 | 2,178 | 2,184 |
| ពាណិជ្ជកម្ម | | 14,292 | 17,576 | 19,698 | 23,355 | 26,543 |
| ឧស្សាហកម្ម | | 860 | 959 | 1,048 | 1,050 | 1,094 |
| ការិយាល័យរដ្ឋាភិបាល | | 1,208 | 1,526 | 1,573 | 1,684 | 1,848 |
| សរុប | 124,269 | 217,640 | 264,799 | 286,758 | 315,533 | 338,567 |

ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ EDC អាចពង្រីកមូលដ្ឋានអតិថិជនរបស់ខ្លួនបានច្រើនប្រភេទ ។

បន្ទាប់មកទៀត លោក រតនៈ បានពិភាក្សាពីគោលដៅអភិវឌ្ឍន៍របស់ EDC/ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សំរាប់ឆ្នាំ២០០៩-២០១៣ ដែលរួមមាន៖

- កាត់បន្ថយចំណាយផលិតកម្ម និងបង្កើនវិសាលភាពនៃការផ្គត់ផ្គង់
- ជំរុញការនាំចូលថាមពលពីប្រទេសជិតខាង
- កសាង និងធ្វើប្រតិបត្តិការលើប្រភពថាមពលសំខាន់ៗ
- តភ្ជាប់បណ្ដាញអគ្គិសនីទូទាំងប្រទេស ពីប្រភពផលិតកម្មទៅនឹងតំបន់ទីក្រុងធំៗ
- កសាងខ្សែបញ្ជូន និងចែកចាយថាមពលនៅទូទាំងប្រទេស

សកម្មភាពអាទិភាពសំរាប់វិស័យនេះ ត្រូវបានគូសរំលេច ។ សំរាប់ប្រព័ន្ធបញ្ជូនថាមពល សកម្មភាពអាទិភាព រួមមាន៖ ការលើកកម្ពស់ស្ថិរភាព គុណភាព និងទំនុកចិត្តនៅភ្នំពេញ កណ្ដាល និងកំពង់ស្ពឺ តាមរយៈការបង្កើតគំរោងខ្សែបញ្ជូនជារង្វង់ ដោយការសាងសង់ខ្សែបញ្ជូនចំនួន ៣ គឺ (១) តាកែវ-កំពត-ក្រុងព្រះសីហនុ (២) ភ្នំពេញ-កំពង់ឆ្នាំង-ពោធិ៍សាត់(អូរសោម)-បាត់ដំបង និង (៣) ភ្នំពេញ-កំពង់ចាម និងការសាងសង់មជ្ឈមណ្ឌលបញ្ជូនអគ្គិសនីទូទាំងប្រទេស ។ សំរាប់អនុប្រព័ន្ធបញ្ជូន បច្ចុប្បន្នមានគំរោងរៀបចំសិក្ខាសាលាមួយ និងការសាងសង់អនុខ្សែបញ្ជូន ដើម្បីបង្កើនការផ្គត់ផ្គង់ថាមពលទៅតំបន់ជនបទ ។

បណ្ដាញចែកចាយ មានគោលដៅមួយចំនួន រួមមាន៖ ទទួលគ្រប់គ្រង ចាត់ចែង និងអភិវឌ្ឍន៍ប្រព័ន្ធនៅមណ្ឌលគីរី ទទួលគ្រប់គ្រង និងវិនិយោគទៅលើប្រព័ន្ធចែកចាយនៅតំបន់អប្សរា ១ និង ២ ក៏ដូចជាខេត្តសៀមរាប លុបបំបាត់ការជាវដុំ (R71) នៅ ១១៦កន្លែង ក្នុងរាជធានីភ្នំពេញ សិក្សា និងវិនិយោគទៅលើប្រព័ន្ធចែកចាយនៅរាជធានីភ្នំពេញ ដើម្បីបង្កើនស្ថិរភាព និងគុណភាពការផ្គត់ផ្គង់ និងបន្តកិច្ចប្រឹងប្រែងកាត់បន្ថយការខាតបង់ក្នុងប្រព័ន្ធចែកចាយ ព្រមទាំងចាត់វិធានការតឹងតែង ទប់ទល់នឹងការតភ្ជាប់អគ្គិសនីដោយខុសច្បាប់ ។

ផលិតកម្មថាមពល មានគោលដៅ៖ បន្តផ្ដល់អាទិភាពដល់វិនិយោគមានចំណាយទាប សំរាប់ជំនួសឲ្យផលិតកម្មមានចំណាយខ្ពស់សព្វថ្ងៃ បន្តដំណើរការសាងសង់រោងចក្រវារីអគ្គិសនី និងរោងចក្រអគ្គិសនីដុតធ្យូងថ្ម និងបង្កើនផលិតភាព ។ ការបង្កើនផលិតភាពរំពឹងថាអាចសំរេចបាន តាមរយៈការបង្កើនប្រសិទ្ធភាពការងារនៃសាខានានារបស់ EDC ដោយការសើរើរៀបចំមុខងារ កាត់បន្ថយការិយាធិបតេយ្យ និងផ្ដល់អាទិភាពដល់ការកែលំអសេវាអតិថិជន ក៏ដូចជាចូលរួមវិភាគទានខាងសង្គម ។

លោក រតនៈ បានបន្តដោយពិភាក្សាពីបញ្ហាមួយចំនួន ដែលកម្ពុជាកំពុងប្រឈម ដើម្បីសំរេចទិសដៅដូចខាងលើ ។ បញ្ហាប្រឈមទី១ គឺការអនុវត្តឱ្យបានទាន់ពេលវេលា នូវផែនការអភិវឌ្ឍន៍ឆ្នាំ២០១០-២០១៣ ។ បន្ទាប់មក គឺការស្វែងរកមូលនិធិមានលក្ខខណ្ឌសម្បទានបន្ថែមទៀត សំរាប់ពង្រីកខ្សែបញ្ជូន និងចែកចាយ ដើម្បីស្រូបយកអគ្គិសនីផលិតបាន ដូចមានចុះក្នុងកិច្ចព្រមព្រៀងទិញថាមពល (Power Purchase Agreements: PPAs) ដែលមានស្រាប់ ។ បញ្ហាប្រឈមផ្សេងទៀត រួមមាន ការកសាងសមត្ថភាពបណ្ដាញអគ្គិសនីទូទាំងប្រទេស ដើម្បីស្រូបយកអគ្គិសនីផលិតបាន និងការដាក់អនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យ ដើម្បីធានាឲ្យផែនការអភិវឌ្ឍន៍អនុវត្តបានទាន់ពេល ។

លោក Kerr បានធ្វើបទបង្ហាញជាបន្ត ដោយធ្វើការពិភាក្សាពីប្រព័ន្ធផ្លូវដែកនៅប្រទេសកម្ពុជា និងបានលើកថា រដ្ឋាភិបាលកម្ពុជា បានចុះកិច្ចសន្យាម៉ៅការឱ្យក្រុមហ៊ុនអយស្ម័យយាន Toll Royal Railway ធ្វើប្រតិបត្តិការអាជីវកម្មលើបណ្ដាញផ្លូវដែកកម្ពុជា ដោយផ្ដល់សម្បទាន ផ្ដាច់មុខរយៈពេល ៣០ឆ្នាំ ។ របៀបរបបអនុវត្តគឺធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង AusAID ផ្ដល់មូលនិធិសំរាប់ការស្ដារផ្លូវដែកឡើងវិញ រីឯសម្បទានិកផ្លូវដែក (Toll) ត្រូវថែទាំហេដ្ឋារចនាសម្ព័ន្ធ និងបើកដំណើរការរថភ្លើង ហើយតាមនេះជួយរំដោះ

មូលនិធិសំរាប់អនុវត្តគំរោងឯទៀត ខាងសេដ្ឋកិច្ច និងសង្គមកិច្ច ។ គំរោងពាក់ព័ន្ធ រួមមាន៖

- ខ្សែខាងត្បូង (២៥៤គីឡូម៉ែត្រ)-ភ្នំពេញទៅកំពង់ផែក្រុងព្រះសីហនុ (ការស្តារជួសជុលខ្សែផ្លូវដែកឡើងវិញ)
- ខ្សែខាងជើង (៣៨០គីឡូម៉ែត្រ) - ភ្នំពេញទៅ សិរីសោភ័ណ្ឌ (ការស្តារជួសជុលខ្សែផ្លូវដែកឡើងវិញ)
- កំណាត់បាត់ខ្សែ (៤៨គីឡូម៉ែត្រ) - សិរីសោភ័ណ្ឌទៅប៉ោយប៉ែត (ការដាក់ខ្សែផ្លូវដែកឡើងវិញ)
- ហេដ្ឋារចនាសម្ព័ន្ធ (ឧ. ការសាងសង់ចំណតថ្មី សំរាប់ផ្ទុកទំនិញ ដឹកតាមមធ្យោបាយច្រើនបែប នៅជាយក្រុងភ្នំពេញ (សំរោង))

លោកបានបន្តធ្វើការពិចារណាពីគំនិតយល់ច្រឡំ ក្នុងការប្រៀបធៀបផ្លូវដែក ជាមួយនឹងផ្លូវថ្នល់ ព្រមទាំងផលចំណេញមួយចំនួននៃការដឹកជញ្ជូនតាមផ្លូវដែក ។ លោកបានវែកញែកថា ចំណាយប្រៀបធៀបផ្លូវថ្នល់/ផ្លូវដែក ជាទូទៅមិនបានឆ្លុះបញ្ចាំងឱ្យសព្វគ្រប់ពីបន្ទុកចំណាយនៃកត្តាខាងក្រៅ ដូចជា ការកកស្ទះ ការបំពុលបរិស្ថាន គ្រោះថ្នាក់ ការបំភាយឧស្ម័ន និងផលប៉ះពាល់ដល់សង្គម និងបរិស្ថាន នោះទេ ។ ជាផលចំណេញ លោកលើកថា ការតភ្ជាប់ផ្លូវដែក កំពង់ផែ និងចំណតផ្ទុកទំនិញដឹកតាមមធ្យោបាយច្រើនបែប បានផ្តល់នូវខ្សែរយៈផ្គត់ផ្គង់ឡូហ្ស៊ីស្ទិកដ៏រលូនមួយ ជួយកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលលើការសាងសង់ និងថែទាំផ្លូវថ្នល់ ព្រមទាំងបង្កើតបានច្រករបៀងមួយមានសុវត្ថិភាពល្អ សំរាប់អ្នកប្រើប្រាស់ផ្លូវថ្នល់ដទៃទៀត ។ ក្រៅពីនេះ ប្រព័ន្ធផ្លូវដែកជំរុញឱ្យមានតំបន់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនសេរី ដោយជួយឱ្យកុងតឺនឺរអាចដឹកបានលឿន ប្រកបដោយសុវត្ថិភាព ប៉ះពាល់បរិស្ថានតិច និងសន្សំសំចៃ រវាងប្រទេសជាច្រើននៅអាស៊ី ។

លោក Kerr ជាអគ្គនាយកក្រុមហ៊ុន Toll ដែលបានទទួលសម្បទានរយៈពេល ៣០ឆ្នាំ ដើម្បីថែទាំប្រព័ន្ធផ្លូវដែក បានវែកញែកពីមូលហេតុដែលក្រុមហ៊ុនលោកចាប់អារម្មណ៍ លើឡូហ្ស៊ីស្ទិកដឹកជញ្ជូននៅកម្ពុជា ដូចតទៅ៖

- កម្ពុជា ស្ថិតក្នុងចំណោមប្រទេសមានកំណើនលឿនបំផុតនៅអាស៊ី និងកំពុងអនុវត្តកំណែទម្រង់សេដ្ឋកិច្ចសំខាន់ៗ ដើម្បីជំរុញ ការអភិវឌ្ឍ
- វិស័យឡូហ្ស៊ីស្ទិកនៅកម្ពុជា មានលក្ខណៈក្មេងខ្ចី ដាច់ដោយដុំ និងទាមទារការស្តាររៀបចំយ៉ាងច្រើន ដើម្បីផ្តល់ការគាំទ្រដល់កំណើន និងការអភិវឌ្ឍនៅក្នុងប្រទេស
- Toll នឹងបង្កើតជាវិធីដឹកជញ្ជូនមួយឆ្លងកាត់មហាតំបន់មេគង្គ ហើយដឹងច្បាស់ថា កម្ពុជា និងបណ្តាញផ្លូវដែកនៅកម្ពុជាមានសារៈសំខាន់បំផុត សំរាប់គំរោងផ្លូវដែកសិង្ហបុរី-គុនមីង
- Toll នឹងរចនារៀបចំ និងដំណើរការអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវដែកមួយដែលសមស្រប មានសុវត្ថិភាពល្អ ជួយសន្សំសំចៃ និងអាចបត់បែនបាន ដែលមានសមត្ថភាពអាចផ្តល់ទុនដោយខ្លួនឯង ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង

ដើម្បីអាចសំរេចគោលដៅកែលម្អប្រព័ន្ធផ្លូវដែកនៅកម្ពុជាបាន រាជរដ្ឋាភិបាលកម្ពុជា ត្រូវបំពេញលក្ខខណ្ឌជាច្រើន មានជាអាទិ៍៖
(ក) ផ្លូវដែកចូលដល់កំពង់ផែផ្ទាល់ - លក្ខខណ្ឌនេះត្រូវបំពេញឲ្យបាននៅចំណតដាក់កុងតឺនឺរ នៅកំពង់ផែក្រុងព្រះសីហនុ ដោយរដ្ឋាភិបាល ត្រូវគាំទ្រតាមការយល់ព្រមឲ្យមានផ្លូវដែកចូលដល់ផ្ទាល់
(ខ) ការទូទាត់ពន្ធគយ - កុងតឺនឺរត្រូវអាចដឹកជញ្ជូនតាម ផ្លូវដែកក្រោមត្រាបញ្ជាក់ពីគយបាន (under-bond)
(គ) ឧបត្ថម្ភធនលើប្រេងឥន្ធនៈ - លក្ខខណ្ឌនេះត្រូវដាក់អនុវត្តចំពោះសម្បទានិកផ្លូវដែក ពីព្រោះរថភ្លើងរត់មួយជើងៗ អាចជំនួសការដឹកជញ្ជូនលើផ្លូវថ្នល់ តាមរថយន្តកាមីញ៉ុងធំៗ ចំនួន ១០០ជើង
(ឃ) ត្រូវកសាងកំណាត់ផ្លូវដែលបាត់នៅក្នុងប្រទេសថៃ
(ង) បែបបទគយ និងការយកពន្ធលើការឆ្លងកាត់ព្រំដែន - កិច្ចព្រមព្រៀងសំរាប់ទំនិញដឹកតាមផ្លូវដែក ត្រូវចរចាគ្នាតាំងពីពេលនេះទៅ
(ច) ប្រព័ន្ធច្បាប់រឹងមាំ - លក្ខខណ្ឌនេះ រួមមាន ការចុះបញ្ជីរថយន្តដឹកជញ្ជូន ការសាយភាយប្រេងឥន្ធនៈ បញ្ហាខាងបរិស្ថាននិងសង្គម និង
(ឆ) ស្តង់ដារសុវត្ថិភាពផ្លូវតឹងរ៉ឹង - លក្ខខណ្ឌទាំងនេះ ត្រូវដាក់អនុវត្តធ្វើការត្រួតពិនិត្យ និងពង្រឹង ហើយរាល់ប្រតិបត្តិការខុសច្បាប់ត្រូវតែបញ្ឈប់ ។

ជាចំណែកមួយនៃវិភាគទានរបស់ខ្លួន Toll នឹងកសាងកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សមួយ ដែលមានខ្លឹមសារដូចតទៅ៖

- ហានិភ័យ និងសុវត្ថិភាព - គោលដៅ គឺការខាតបង់ពេលវេលាដោយរបួសកម្រិតសូន្យ
- សម្ភារៈការពារបុគ្គល - ណែនាំបង្ហាញ ដាក់អនុវត្ត និងពង្រឹងអនុវត្ត
- ការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព - អភិវឌ្ឍ និងផ្តល់ជូនសំរាប់វិស័យនីមួយៗ
- ការអនុវត្តល្អខាងបរិស្ថាន - អភិវឌ្ឍប្រព័ន្ធ និងធានាការប្រតិបត្តិតាម
- ការពិនិត្យសុខភាព - មុនពេលឲ្យចូលធ្វើការ និងតាមពេលកំណត់
- ការយល់ដឹងរបស់សហគមន៍ - ត្រូវបង្កើតកម្មវិធីផ្សេងៗ និងធ្វើការបង្ហាញជូននៅតាមបណ្តាញផ្លូវដែក

លោក Kerr បានបញ្ចប់បទបង្ហាញ ដោយវែកញែកថា រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាខាងគោលនយោបាយនៅពេលនេះតែម្តង បើពុំនោះទេ ធនាគារអភិវឌ្ឍន៍អាស៊ី AusAID និងវិស័យឯកជន នឹងត្រូវចំណាយអស់ជាង ២០០លានដុល្លារ ដើម្បីស្តារកសាងឡើងវិញនូវបណ្តាញផ្លូវដែកមួយ ដែលមិនអាចធ្វើអាជីវកម្មដឹកជញ្ជូនទំនិញឲ្យរស់រាននឹងមានចីរភាព ជាលក្ខណៈពាណិជ្ជកម្មបាន ។ ដូច្នេះ ត្រូវចាត់វិធានការជាបន្ទាន់ ។

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

អត្ថបទនេះ បង្ហាញពីបម្រែបម្រួលសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនក្នុងពិភពលោក និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ី នៅត្រីមាសទី៤ ឆ្នាំ២០០៩ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៤ ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក កើនឡើង ០,១% ធៀបនឹងត្រីមាសមុន ដែលបានធ្លាក់ចុះអស់ ២,៥% ។ កំណើននេះ បានមកពីការរួមចំណែកជាវិជ្ជមាននៃវិនិយោគលើស្តុកទំនិញឯកជន ការនាំចេញ ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន និងវិនិយោគជាប់លាប់លើសំណង់មិនមែនសម្រាប់ស្នាក់នៅ ។ ក្នុងពេលជាមួយគ្នា ផសស ពិត នៅតំបន់អឺរ៉ូ មានកំណើនវិជ្ជមាន ០,១% បន្ទាប់ពីបានធ្លាក់ចុះអស់បីត្រីមាសកន្លងទៅ ។ ផលិតកម្មប្រចាំឆ្នាំនៅជប៉ុន រួមចុះ ១,៤% ប៉ុន្តែនៅប្រសើរជាងត្រីមាសមុន (-៤,៧%) ដោយសារមានកំណើនចំណាយសាធារណៈ ចំណាយឯកជន និងតំរូវការពីប្រទេសក្រៅ ។ នៅត្រីមាសទី៤ នេះដែរ ផសស ពីមួយឆ្នាំទៅមួយឆ្នាំរបស់ចិន បន្តកើនឡើងយ៉ាងខ្លាំង ដល់ ១០,៧% ធៀបនឹង ៨,៩% កាលពីត្រីមាសមុន ។ ប្រភពចំបងនៃកំណើននេះគឺ ដំណើរការដ៏ល្អនៃវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ដែលភាគច្រើនទទួលបានពីកញ្ចប់ថវិកាជំរុញរបស់រដ្ឋាភិបាល និងការស្ទុះឡើងវិញនៃចំណាយលើការអភិវឌ្ឍអចលទ្រព្យ ។ នៅហុងកុង ក៏មានសញ្ញាណនៃការងើបសេដ្ឋកិច្ចដែរ ដោយ ផសស កើនឡើង ២,៦% ។ កំលាំងងើបឡើងវិញនេះ អាចមើលឃើញច្បាស់តាមទិន្នន័យនៃភាពគ្មានការងារធ្វើ និងពាណិជ្ជកម្មក្រៅប្រទេស ។ ស្រដៀងគ្នានេះដែរ សេដ្ឋកិច្ចកូរ៉េខាងត្បូង មានដំណើរការខ្លាំងឡើងវិញ ជាមួយនឹងកំណើនផលិតកម្ម ៦,១% ។ និន្នាការកើនឡើងជាបន្តបន្ទាប់នេះ បានមកពីកំណើនជាវិជ្ជមាននៃចំណាយប្រើប្រាស់ឯកជន និងវិនិយោគលើសម្ភារៈសម្រួលការ (facilities investment) ។ ក្នុងពេលជាមួយគ្នា តៃវ៉ាន់ មានសកម្មភាពសេដ្ឋកិច្ចខ្លាំងជាងគេ ធៀបនឹងប្រទេសឯទៀតនៅក្នុងតំបន់ ដោយទទួលបានកំណើន ផសស ពិត ៩,២%ធៀបនឹង -១,៣% កាលពីត្រីមាសមុន ។

សញ្ញាណនៃការងើបសេដ្ឋកិច្ច អាចមើលឃើញច្បាស់នៅម៉ាឡេស៊ី និង ថៃ ដែលមានកំណើនផលិតកម្មជាវិជ្ជមានដល់ ៤,៥% (ម៉ាឡេស៊ី) និង ៥,៨% (ថៃ) ។ នេះជាកំណើនលើកដំបូងនៃផលិតកម្មនៅប្រទេសថៃ បន្ទាប់ពីបានធ្លាក់ចុះអស់ ៤ត្រីមាស ជាបន្តបន្ទាប់ ។ កត្តាចំបងៗនាំឱ្យមានកំណើននេះគឺ កំណើនការនាំចេញសុទ្ធ កំណើន ១,៤% នៃចំណាយប្រតិបត្តិការតាមផ្ទះ និងកំណើន ៥,២% នៃចំណាយប្រើប្រាស់របស់រដ្ឋាភិបាល ប៉ុន្តែមានការកាត់កងចុះខ្លះវិញ ដោយសារការធ្លាក់ចុះ ៣,៤% នៃវិនិយោគឯកជន ។

ផលិតកម្មសរុបនៅសិង្ហបុរី កើន ៤,០% ដោយសារកំណើនការនាំចេញ ពិសេសទៅកាន់សហរដ្ឋអាមេរិក (ដោយផ្ទាល់ និងដោយប្រយោល) ។ ផសស ពីមួយឆ្នាំទៅមួយឆ្នាំនៅឥណ្ឌា កើន ៥,៤% ដោយសារការនាំចេញកើនជាខ្លាំង ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០០៩ សំពាធបរិត្តផរណាបន្តកើតមាននៅប្រទេសសិង្ហបុរី តៃវ៉ាន់ និង ជប៉ុន ។ អតិផរណាថ្លៃទំនិញប្រើប្រាស់សរុបនៅជប៉ុន បន្តមានកំរិតទាបត្រឹម -២,០% តែបានកើនឡើងបន្តិចហើយ ធៀបនឹងអត្រា -២,២% កាលពីត្រីមាសមុន ។ គំលាតកាន់តែធំឡើងរវាងសមត្ថភាពផលិតកម្ម និងតំរូវការជាក់ស្តែងនៅតែជាកត្តាដែលបង្កបរិត្តផរណានៅជប៉ុន ។ ផ្ទុយទៅវិញ អតិផរណាថ្លៃទំនិញប្រើប្រាស់ នៅសហរដ្ឋអាមេរិក បានក្លាយជាវិជ្ជមានវិញ គឺ ១,៤% ធៀបនឹង -១,៦% នៅត្រីមាសមុន ។ អតិផរណានៅតំបន់អឺរ៉ូ ក៏មានតួលេខវិជ្ជមានវិញដែរ គឺ ០,៤% ធៀបនឹង -០,៣% នៅត្រីមាសមុន ។

នៅត្រីមាសទី៤ ប្រាក់ដុល្លារអាមេរិកនៅថេរ ធៀបនឹងប្រាក់យន់ចិន និង ដុល្លារហុងកុង ប៉ុន្តែវាធ្លាក់ថ្លៃ ៥,៨% ទល់នឹងប្រាក់វ៉ុនកូរ៉េ ១,៥% ទល់នឹងប្រាក់ដុល្លារតៃវ៉ាន់ ២,៨% ទល់នឹងប្រាក់អឺរ៉ូ និង ៤,០% ទល់នឹងប្រាក់យេនជប៉ុន បើធៀបនឹងត្រីមាសមុន ។ ដោយឡែក ១ដុល្លារអាមេរិក ប្តូរបាន ៨៩,៧៨យេន រឺ ១១៦៧,៧៧វ៉ុន ។

## ថ្លៃទំនិញប្រើប្រាស់លើទីផ្សារពិភពលោក

នៅត្រីមាសទី៤ ឆ្នាំ២០០៩ ផលិតផលកសិកម្មសំខាន់ៗ ក្រៅពីសណ្តែកសៀងឡើងថ្លៃគួរកត់សំគាល់ បើធៀបនឹងត្រីមាសទី៣ ។ ពោត (US លេខ២) ឡើងថ្លៃ ១៤,៥% ដល់ ១៦៨,១៣ដុល្លារ/តោន រីឯប្រេងឆា ឡើងថ្លៃ ១០,០% ហើយអង្ករ (ថៃ 100% B) ឡើងថ្លៃ ៨៥% ។ សណ្តែកសៀង ធ្លាក់ថ្លៃ ៥,០% ធៀបនឹងត្រីមាសមុន ។ ប្រេងឆៅ ឡើងថ្លៃ ៨,១% ដល់ ៧៣,៨ដុល្លារ/ធុង ចំណែកឯ សាំង ឡើងថ្លៃ ៥,៨% ដល់ ០,៤៩ដុល្លារ/លីត្រ និងម៉ាស៊ូត ឡើងថ្លៃ ៩,៨% ដល់ ០,៥១ដុល្លារ/លីត្រ ។

*រៀបរៀងដោយ*
*សាំង ច័ន្ទហង្ស និង ស្រី បុប្ផារ័ត្ន*

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 6.1 | 5.2 | 4.4 | 3.9 | 4.2 | 5.4 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | 4.7 | 0.1 | -6.2 | -3.9 | -1.2 | 4.5 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | -0.6 | -4.2 | -10.1 | -3.5 | 0.8 | 4.0 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | 3.9 | -4.3 | -7.1 | -4.9 | -2.8 | 5.8 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 9.0 | 6.8 | 6.1 | 7.9 | 8.9 | 10.7 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | 1.7 | -2.5 | -7.8 | -3.8 | -2.2 | 2.6 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | 3.8 | -3.6 | -4.4 | -2.2 | 0.4 | 6.1 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | -1.0 | -8.4 | -10.2 | -7.5 | -1.3 | 9.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | 0.6 | -1.3 | -2.5 | -4.8 | -4.7 | 0.1 |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | -0.5 | -4.6 | -9.1 | 0.6 | -4.7 | -1.4 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | -0.5 | -6.3 | -2.6 | -3.9 | -2.5 | 0.1 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 21.7 | 15.7 | 4.3 | -4.8 | -3.0 | 1.7 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 11.9 | 11.4 | 8.5 | 5.6 | 2.76 | 2.6 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 8.4 | 5.9 | 3.7 | 1.3 | -2.26 | -0.2 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 6.5 | 5.5 | 2.1 | -0.5 | -0.4 | -0.3 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | 7.2 | 2.2 | -0.2 | -2.8 | -2.13 | 1.9 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 29.0 | 23.6 | 15.1 | 6.2 | 2.6 | 4.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 5.3 | 2.5 | -0.6 | 1.5 | -1.26 | 0.7 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 4.6 | 2.3 | 1.7 | -0.1 | -0.86 | 1.3 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 5.5 | 4.5 | 3.9 | 2.8 | 2.0 | 2.4 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 4.5 | 1.9 | 0.0 | -0.8 | -1.33 | -1.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 3.8 | 2.3 | 1.0 | 0.9 | -0.36 | 0.4 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | 2.2 | 1.0 | -0.1 | -1.0 | -2.2 | -2.0 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | 5.3 | 1.5 | -0.2 | -0.9 | -1.63 | 1.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.3 | 4092.5 | 4103.2 | 4062.7 | 4054.2 | 4117.4 | 4089.8 | 4108.0 | 4128.55 | 4164.44 | 4163.10 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938 | 9705 | 9134 | 9419 | 9699.0 | 9216.3 | 11,060 | 11,630.8 | 10,225.0 | 9887 | 9472.44 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.79 | 3.67 | 3.31 | 3.34 | 3.37 | 3.56 | 3.63 | 3.52 | 3.50 | 3.40 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.43 | 1.49 | 1.51 | 1.45 | 1.44 | 1.39 |
| ថៃ (បាត) | 40.2 | 40.2 | 37.9 | 32.22 | 33.36 | 34.0 | 34.83 | 35.29 | 33.98 | 33.96 | 33.30 |
| វៀតណាម (ដុង) | 15,777 | 15,859 | 15,994 | 16,030 | 16,382 | 16,517 | 16,537 | 16,954 | 17,801 | 17,841 | 18,472 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.82 | 6.83 | 6.84 | 6.83 | 6.83 | 6.83 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.8 | 7.78 | 7.77 | 7.75 | 7.75 | 7.75 | 7.75 | 7.75 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145 | 1024 | 955 | 929.04 | 1137.23 | 1207.0 | 1367.2 | 1412.5 | 1273.9 | 1239.04 | 1167.77 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់- T$) | 33.6 | 32.1 | 32.5 | 32.85 | 31.54 | 31.20 | 33.0 | 34.0 | 33.1 | 32.77 | 32.29 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.7 | 0.84 | 0.71 | 1.32 | 0.76 | 0.71 | 0.70 | 0.68 |
| ជប៉ុន (យ៉េន) | 108.2 | 110.2 | 116.4 | 117.8 | 102.46 | 104.03 | 96.1 | 93.72 | 95.95 | 93.58 | 89.78 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០០៩(មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No. 2) - US (USD/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 254.99 | 181.22 | 183.12 | 171.16 | 146.85 | 168.13 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 949.03 | 564.50 | 636.53 | 719.35 | 659.16 | 732.33 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 657.88 | 519.41 | 522.13 | 499.45 | 307.31 | 569.00 |
| សណ្តែកសៀង (US No. 1) - US (USD/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 529.30 | 382.72 | 434.40 | 420.10 | 411.18 | 390.43 |
| ប្រេងឆៅ - OPEC spot (USD/តោន) | 33.5 | 50.14 | 61.58 | 69.25 | 95.44 | 115.30 | 55.23 | 42.34 | 57.46 | 68.32 | 73.86 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.9 | 42.19 | 47.70 | 53.58 | 62.22 | 81.27 | 34.52 | 31.97 | 43.11 | 46.92 | 49.64 |
| ម៉ាស៊ូត (ស្តាន់ដ៉ាតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.2 | 88.46 | 46.98 | 34.17 | 40.51 | 46.46 | 51.03 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០០៩ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់សរុប កើនឡើង ១០ដង ធៀបនឹងត្រីមាសមុន ដោយសារកំណើន ១០,៣ដង នៃអនុមតិសំរាប់វិស័យឧស្សាហកម្ម និងកំណើន ២២ដង សំរាប់វិស័យសេវាកម្ម ប៉ុន្តែស្របពេលអនុមតិសំរាប់វិស័យកាត់ដេរ ធ្លាក់ចុះ ៣៥% ។ ក្នុងអំឡុងពេលនោះពុំមានអនុមតិវិនិយោគ សំរាប់វិស័យទេសចរណ៍ ឬសណ្ឋាគារឡើយ ។ ក្នុងវិស័យឧស្សាហកម្ម ផ្នែកកាត់ដេរ ធ្លាក់ចុះមកត្រឹម ១៤,២៤លានដុល្លារ ស្បែកជើង ធ្លាក់ចុះ ៣៣,៤% មកត្រឹម ២,៤៨លានដុល្លារ ប៉ុន្តែស្រោមជើង កើនដល់ ២,៨លានដុល្លារ ។ អនុមតិផ្នែកថាមពលកើនឡើងពី ២,៥២លានដុល្លារ ដល់ ៥៤០លានដុល្លារ ។ នៅត្រីមាសមុន ពុំមានអនុមតិសំរាប់ការកែច្នៃម្ហូបអាហារ ឬឈើឡើយ ប៉ុន្តែនៅត្រីមាសនេះ អនុមតិសំរាប់ ការកែច្នៃឈើមានដល់ ១០,៣លានដុល្លារ ហើយសំរាប់ការកែច្នៃម្ហូបអាហារ មានដល់ ២៣,០២លានដុល្លារ រីឯអនុមតិវិនិយោគសំរាប់ផ្នែកឧស្សាហកម្មផ្សេងៗទៀត កើន ៥,៨ដង ដល់ ៨៥,៩១លានដុល្លារ ។ វិស័យសេវាកម្ម កើនដល់ ៣៤៧៥,៧៧លានដុល្លារ ហើយខាងកសិឧស្សាហកម្ម កើនដល់ ៩៤,៣៧លានដុល្លារ ។ អនុមតិវិស័យសំណង់ កើន ២,២ដង ធៀបនឹងត្រីមាសមុន ដល់ ៦៦,៨លានដុល្លារ ដោយសារកំណើន ៣,៥ដង នៃអនុមតិគម្រោងសាងសង់ផ្ទះ និងភូមិគ្រឹះ ដល់ ៩,៨លានដុល្លារ និងគម្រោងផ្ទះល្វែង ដល់ ២៨លានដុល្លារ ។ អនុមតិសម្រាប់សំណង់ផ្សេងៗទៀត កើន ១៣៨% ដល់ ២៩លានដុល្លារ ។ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៨ អនុមតិគម្រោងសាងសង់ផ្ទះនិងភូមិគ្រឹះ ធ្លាក់ចុះ ៧៥% ហើយអនុមតិគម្រោងផ្ទះល្វែង ធ្លាក់ចុះ ៥៣% រីឯសំណង់ផ្សេងៗទៀត ធ្លាក់ចុះ ៨៩% ។

នៅត្រីមាសទី៤ នេះដែរ ចំនួនភ្ញៀវមកដល់កម្ពុជាសរុប កើនឡើង ២១% ធៀបនឹងត្រីមាសមុន ដល់ ៥៨៧.៦៣៧នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាស មានចំនួន ៣០៨.១២២នាក់ ឬ កើន ២៥% ក្នុងនោះ ភ្ញៀវចូលមកតាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កើនដល់ ១៤៨.០២៧នាក់ ហើយតាមអាកាសយានដ្ឋានសៀមរាប កើនដល់ ១៦០.០៩៥នាក់ ។ ភ្ញៀវចូលមកតាមផ្លូវគោក កើន ១៦% ដល់ ២៧៩.៥១៥នាក់ ។ នៅ៣ត្រីមាសបន្តបន្ទាប់គ្នានេះ ក្នុងចំណោមភ្ញៀវមកពីប្រទេសអាស៊ាន ភ្ញៀវមកពីវៀតណាម មានច្រើនជាងគេ (៨៧.៥០៨នាក់) បន្ទាប់មកគឺ ភ្ញៀវថៃ (២៥.៩៨២នាក់) រីឯភ្ញៀវប្រ៊ុយណេ មានតិចជាងគេ (១៣៦នាក់) ។

នៅត្រីមាសទី៤ នេះដែរ ការនាំចេញសរុបរបស់កម្ពុជាកើន ១៧៥% ដល់ ៦៧៥,៣លានដុល្លារ ដោយសារការនាំចេញសំលៀកបំពាក់ កើន ១៧២% ដល់ ៦៥២,៩លានដុល្លារ ការនាំចេញកៅស៊ូ កើន ២,៣% ដល់ ១៦,២លានដុល្លារ និងការនាំចេញឈើ កើនពីសូន្យនៅត្រីមាសមុន ដល់ ១,២លានដុល្លារ ។ ការនាំចេញត្រី កើនពី ០,៤លានដុល្លារ ដល់ ៥,០លានដុល្លារ ។ ការនាំចូលផលិតផលប្រេងកាត កើន ២៨៤% ដល់ ៣៤១,៦លានដុល្លារ ហើយការនាំចូលសម្ភារៈសំណង់ កើន ២៧៥% ដល់ ៣៧,១លានដុល្លារ ។ ជញ្ជីងពាណិជ្ជកម្មមានឱនភាព ៧២១,២លានដុល្លារ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០០៩ អតិរេកថវិការដ្ឋាភិបាល កើន ១០៩% ដល់ ៩០,២ពាន់លានរៀល ។ ការប្រមូលចំណូល កើន ១៣,៦% ធៀបនឹងត្រីមាសមុន ។ ចំណូលចរន្ត កើន ១៣,៩% ដល់ ១៣៣៧,៧ពាន់លានរៀល ប៉ុន្តែចំណូលមូលធន ធ្លាក់ចុះ ១៤,៣% មកត្រឹម ៨,៤៣ពាន់លានរៀល ។ នៅក្នុងចំណូលចរន្ត ចំណូលពន្ធកើន ២២,៤% ដល់ ១២២៤,១ពាន់លានរៀល ដោយសារកំណើនពន្ធក្នុងស្រុក ១០,៥% ដល់ ៨០៨,៥ពាន់លានរៀល និងកំណើនពន្ធលើពាណិជ្ជកម្មអន្តរជាតិ ១៣,២% ដល់ ៣០៣,៤ពាន់លានរៀល ។ ចំណូលមិនមែនពន្ធ កើន ២៨,២% ពី ១៧៦,១ពាន់លានរៀល ដល់ ២២៥,៧ពាន់លានរៀល ។ ចំណាយសរុបថយចុះ ១០% ដោយសារចំណាយមូលធន ថយចុះ ១៦,៤% មកត្រឹម ៦៣៤,៩ពាន់លានរៀល ស្របពេលដែលចំណាយចរន្តកើន ៣,២% ដល់ ១៣៣២,៣ពាន់លានរៀល ។ ចំណាយលើបៀវត្សរ៍ កើន ២២,០% រីឯចំណាយជាឧបត្ថម្ភធន និងប្រាក់ឧបត្ថម្ភខាងសង្គមកិច្ច ធ្លាក់ចុះ ២៨% ។

## អតិផរណា និង អត្រាប្តូរប្រាក់

នៅត្រីមាសទី៤ នេះ អតិផរណាប្រចាំឆ្នាំ កើនដល់ ១,៧% ធៀបនឹង -៣,០% កាលពីត្រីមាសមុន ។ ថ្លៃអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ១,៨% ថ្លៃដឹកជញ្ជូន កើន ២,៤% ថ្លៃសំលៀកបំពាក់ និងគ្រឿងសំរាប់ពាក់នៅជើង កើន ៣,១% ថ្លៃសង្ហារឹម និងប្រតិបត្តិការក្នុងផ្ទះ កើន ៤,៥% ថ្លៃថែទាំសុខភាព កើន ៥,៨% និង ថ្លៃអប់រំ កើន ១០,១% ។ ថ្លៃស្នាក់នៅ និងទឹកភ្លើង ធ្លាក់ចុះ ៣,៨% ថ្លៃទូរគមនាគមន៍ ធ្លាក់ចុះ ៧,៥% និង ថ្លៃលំហែកំសាន្ត និងវប្បធម៌ ធ្លាក់ចុះ ០,៦% ។

នៅត្រីមាសទី៤ នេះ ប្រាក់រៀល ឡើងថ្លៃ ០,២% ទល់នឹងប្រាក់ដុល្លារអាមេរិក ធៀបនឹងត្រីមាសមុន ដោយប្តូរបាន ៤១៥៧,៣ រៀល/ដុល្លារអាមេរិក និង ឡើងថ្លៃ ២,៥% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១២៦,០រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀល ធ្លាក់ថ្លៃ ២,១% ដោយប្តូរបាន ២៣,០រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

ទ្រព្យសកម្មបរទេសសុទ្ធ កើន ៥,៦% ដល់ ១៤.៦៥៥ពាន់លានរៀល ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ៥១% ដល់ ១៥៧៣ពាន់លានរៀល ។ ឥណទេយ្យលើរដ្ឋាភិបាលសុទ្ធ ថយចុះ ៨,៦% មកនៅ -២២៥២ពាន់លានរៀល ។ រូបិយវត្ថុទូទៅ (M2) កើន ១៣%

ដោយសារកំណើនរូបិយវត្ថុនៅក្រៅធនាគារ (១៣%) និងប្រាក់បញ្ញើបើកបានភ្លាម (៣,០%) ។

## ស្ថានភាពគ្រីក្រ

នៅខែកុម្ភៈ ២០១០ ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់ក្រុមពលករមិនមែនកាត់ដេរ កើន ៣,៣% ដល់ ៨៣៤២រៀល ធៀបនឹង៨០៧៤រៀល កាលពីខែកុម្ភៈ ២០០៩ ដែលជាកំណើនដ៏ប្រសើរមួយ បន្ទាប់ពីបានធ្លាក់ចុះ ២១% នៅខែវិច្ឆិកា ២០០៩ ។ ក្នុងចំណោម៩ក្រុមពលករខាងលើ មានតែ ៣ក្រុម ប៉ុណ្ណោះ ដែលមានការធ្លាក់ចុះប្រាក់ចំណូល ។ អ្នកស៊ីឈ្នួលធ្វើស្រែ រងការប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដោយប្រាក់ចំណូលពិតបានធ្លាក់ចុះ ២៤% ហើយបន្ទាប់មកគឺ អ្នកលីសែង(៥%) និង អ្នករត់ម៉ូតូឌុប (៣%) ។ ចំណូលរបស់ក្រុមកម្មករសំណង់មានជំនាញ អ្នកលក់បន្លែតូចតាច អ្នកធាក់ស៊ីក្លូ អ្នកបំរើតុភោជនីយដ្ឋាន អ្នករើសអេតចាយ និងកម្មករសំណង់គ្មានជំនាញ មានការកើនឡើង ។

ចំណូលពិតជាមធ្យមរបស់ អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប និងអ្នកស៊ីឈ្នួលធ្វើស្រែ បានរើបឡើងវិញ បន្ទាប់ពីបានធ្លាក់ចុះអស់ជិតមួយឆ្នាំមក ។ ទោះយ៉ាងណាក្តី ចំណូលពិតរបស់ អ្នករត់ម៉ូតូឌុប និងអ្នកស៊ីឈ្នួលធ្វើស្រែ មិនទាន់ឡើងដល់កម្រិតដែលធ្លាប់ទទួលបានកាលពីឆ្នាំមុនឡើយ ។ ចំណូលពិតរបស់កម្មករសំណង់គ្មានជំនាញបានធ្លាក់ចុះវិញ បន្ទាប់ពីបានកើននៅខែឧសភា ២០០៩ នេះ ដល់ចំនុចខ្ពស់បំផុត ដែលមិនធ្លាប់មានក្នុងរយៈពេលបីឆ្នាំចុងក្រោយ ។

នៅខែកុម្ភៈ ២០១០ ចំណាយប្រចាំថ្ងៃពិតរបស់ ៩ក្រុមពលករមិនមែនកាត់ដេរ គឺ ៣៧២៥រៀល ឬ កើន ២,៥% ធៀបនឹង ខែកុម្ភៈ ២០០៩ ប៉ុន្តែក្នុងនេះ ចំណាយរបស់កម្មករសំណង់មានជំនាញធ្លាក់ចុះ ៣% និង របស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ១៥% ។ ធៀបនឹងខែវិច្ឆិកា ២០០៩ ចំណាយជាមធ្យមរបស់ពលករទាំង ៩ក្រុម កើន ១២% ប៉ុន្តែវាបានធ្លាក់ចុះអស់ ៧% នៅចន្លោះខែវិច្ឆិកា ២០០៨ និង កុម្ភៈ ២០០៩ ។

ក្រុមចុះអង្កេត បានស្នើឲ្យអ្នកឆ្លើយសំភាសន៍ប្រមើលថាតើចំណូលរបស់ខ្លួននៅឆ្នាំ២០១១ នឹងប្រែប្រួលយ៉ាងណា ធៀបនឹងឆ្នាំ២០០៩ ។ នៅខែកុម្ភៈ ២០១០ អ្នកឆ្លើយសំភាសន៍ដែលមិនមានយោបល់អ្វីពីរឿងប្រាក់ចំណូលរបស់ខ្លួនក្នុងឆ្នាំ២០១១ មានត្រឹម ២៩% ប៉ុណ្ណោះ គឺ ថយចុះ ១៤ឯកតាភាគរយ (percentage point) ធៀបនឹងកាលពីខែឧសភា ២០០៩ ។[១] សមាមាត្រពលករមិនមែនកាត់ដេរដែលគិតថា ចំណូលរបស់ខ្លួនក្នុងឆ្នាំ២០១១ នឹងចុះទាបជាងឆ្នាំ២០០៩ បានកើនដល់ ២៨% ដែលជាតួលេខខ្ពស់បំផុតស្តីពីចំណូលរំពឹងទុក ។ សំរាប់ខែកុម្ភៈ ២០១០ ផលបូកតួលេខទាំងពីរ ដែលបង្ហាញពីភាពមិនច្បាស់លាស់នៃចំណូល នៅឆ្នាំខាងមុខ គឺ ៥៦% ធៀបនឹង ៦៧% កាលពីខែឧសភា ២០០៩ ។

នៅខែកុម្ភៈ ២០១០ ចំណូលប្រចាំថ្ងៃពិតរបស់ពលករក្នុងវិស័យទេសចរណ៍ ធ្លាក់ចុះមកត្រឹម ២១.១៤៧រៀល គឺប្រែប្រួលខុសពីលទ្ធផលអង្កេតនៅខែសីហា និងវិច្ឆិកា២០០៩ ដែលកាលនោះវាមានកំណើន ។ ទោះយ៉ាងណាក្តី ចំណូលប្រចាំថ្ងៃរបស់ពួកគេ កើន ៩០% បើធៀបនឹងខែឧសភា ២០០៩ ។ ចំណាយប្រចាំថ្ងៃពិតរបស់ពួកគេ បានថយចុះមកត្រឹម ៥៦០០រៀល ធៀបនឹង ៨១៤៧រៀល នៅខែវិច្ឆិកា ២០០៩ ។ នៅខែកុម្ភៈ ២០១០ ចំណូលប្រចាំថ្ងៃពិតរបស់ពលករចំណាកស្រុក ឡើងដល់កម្រិតខ្ពស់បំផុត គឺ ៩២៨៤រៀល ឬ កើន ៣៧% ធៀបនឹងខែមីនា ២០០៩ ។ ស្រដៀងគ្នានេះដែរ ចំណាយប្រចាំថ្ងៃពិតរបស់ពលករចំណាកស្រុក ឡើងដល់ ២៥៧៦រៀល ដែលជាតួលេខខ្ពស់បំផុតចាប់តាំងពី CDRI បាន បញ្ចូលក្រុមពលករនេះ នៅក្នុងអង្កេតប្រចាំត្រីមាសរបស់ខ្លួនកាលពី ខែឧសភា ២០០៩ ។

នៅខែកុម្ភៈ ២០១០ សមាមាត្រនៃពលករចំណាកស្រុក និងពលករក្នុងវិស័យទេសចរណ៍ ដែលរំពឹងថា ចំណូលរបស់ខ្លួននឹងថយចុះក្នុងឆ្នាំ២០១១ កើនដល់ ៤៨% ដែលជាតួលេខខ្ពស់បំផុតគិតតាំងពីពេលចាប់ធ្វើអង្កេតមក ។ លទ្ធផលនេះ ផ្ទុយគ្នានឹងការរើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិមកកម្ពុជាក្នុងឆ្នាំ២០០៩ ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់កម្មកររោងចក្រកាត់ដេរ បានកើនឡើងក្នុងអង្កេតបន្តបន្ទាប់គ្នាទាំង ៣លើក រហូតដល់ខែកុម្ភៈ ២០១០ ។ សមាមាត្រកម្មករកាត់ដេរ ដែលនិយាយថា មិនបានធ្វើការម៉ោងបន្ថែមក្នុងអំឡុងមួយសប្តាហ៍មុនពេលសម្ភាសន៍ បានថយចុះមកត្រឹម ៣០% ធៀបនឹង ៤៩% កាលពីខែកុម្ភៈ ២០០៩ ។ រីឯកម្មករដែលប្រាប់ថា បានធ្វើការម៉ោងបន្ថែមញឹកញាប់ក្នុងអំឡុងមួយសប្តាហ៍មុននោះ កើនដល់ ៣៧% ឬ ២២% ច្រើនជាងសម្ភាសន៍កាលពីខែកុម្ភៈ ២០០៩ និង ១១% ច្រើនជាងកាលពីខែកុម្ភៈ ២០០៧ ។

នៅខែកុម្ភៈ ២០១០ ចំណាយប្រចាំថ្ងៃពិតជាមធ្យមរបស់កម្មកររោងចក្រកាត់ដេរ គឺ ៤៧៧៤រៀល ឬ ២% ទាបជាងកាលពីខែកុម្ភៈ ២០០៩ ។ ការធ្លាក់ចុះនេះ បង្កមួយផ្នែកមកពីការបង្កើនប្រាក់សន្សំ និងប្រាក់ផ្ញើទៅផ្ទះ ។ ក្នុងខែកុម្ភៈនេះដែរ ប្រាក់សន្សំប្រចាំថ្ងៃពិតជាមធ្យមរបស់កម្មកររោងចក្រកាត់ដេរ ឡើងដល់២៥២៤រៀល ឬ កើន ១២% ធៀបនឹង ខែកុម្ភៈ ២០០៩ ។ អង្កេតក្នុងខែកុម្ភៈ២០១០ រកឃើញថា ៦០% នៃកម្មកររោងចក្រកាត់ដេរផ្ញើប្រាក់ជាមធ្យម ៩៤.០៧៨រៀល/ខែ ទៅឲ្យគ្រួសារពួកគេនៅជនបទ និងតំបន់ដាច់ស្រយាល ហើយតួលេខនេះខ្ពស់ជាងកាលពីខែកុម្ភៈ ២០០៩ ប្រមាណ ១៨.១៣៩រៀល ឬ ២៤% ។

អង្កេតនៅខែកុម្ភៈ ២០១០ បង្ហាញថា សមាមាត្រកម្មកររោងចក្រកាត់ដេរ ដែលប្រមើលឃើញល្អពីចំណូលរបស់ខ្លួនក្នុងឆ្នាំ ២០១១ មាន ២៨% ដែលជាតួលេខខ្ពស់បំផុតធៀបនឹងអង្កេត ៤លើកកន្លងទៅ ។ ចំពោះអត្រាអ្នកដែលឆ្លើយថា ចំណូលរបស់ខ្លួនប្រហែលនៅដដែលនោះ បានកើនឡើងរហូតដល់ ៣១% រីឯសមាមាត្រអ្នកគ្មានគំនិតយោបល់អ្វី អំពីចំណូលរបស់ខ្លួននៅឆ្នាំ ២០១១ វិញ បានថយចុះមកត្រឹម ២៦% ឬប្រហែលពាក់កណ្តាលនៃតួលេខអង្កេតពីមុន (វិច្ឆិកា ២០០៩) និង ១១% ទាបជាងតួលេខអង្កេតកាលពីខែឧសភា ២០០៩ ។ តួលេខនេះបង្ហាញថា ការប្រមើលពីប្រាក់ចំណូលក្នុងវិស័យកាត់ដេរ បានប្រែប្រួលប្រសើរឡើងបន្តិចហើយ ។

*រៀបរៀងដោយ ស្រី បុប្ផារ័ត្ន, ប៉ុន ដូរីណា និង គុង គឹមស៊ុន*

១ ក្នុងអង្កេតនៅខែឧសភា សីហា និងវិច្ឆិកា ២០០៩ គេបានស្នើឲ្យអ្នកឆ្លើយសំភាសន៍ប្រាប់ពីប្រាក់ចំណូលរំពឹងទុករបស់ខ្លួនសំរាប់ឆ្នាំ២០១០ ធៀបនឹងឆ្នាំ២០០៨ ។

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៤-០៩

| | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 12.3 | 26.8 | 498.0 | 135.6 | 52.3 | 16.7 | 18.6 | 4.4 | 175.3 | 0.0 | 176.1 | 94.4 |
| ឧស្សាហកម្ម | 187.9 | 914.6 | 365.3 | 709.1 | 52.9 | 95.0 | 91.6 | 485.4 | 257.7 | 39.4 | 60.6 | 685.5 |
| *កាត់ដេរ* | *132.6* | *174.4* | *89.4* | *170.7* | *42.3* | *47.8* | *31.3* | *21.4* | *16.4* | *35.0* | *21.9* | 14.2 |
| សេវាកម្ម | 91.8 | 155.5 | 2939.1 | 1742.5 | 148.2 | 4064.9 | 4450.5 | 1339.6 | 495.6 | 0.0 | 150.2 | 3475.8 |
| *សណ្ឋាគារ និងទេសចរណ៍* | *55.9* | *102.6* | *345.0* | *1048.3* | *93.7* | *4015.0* | *3481.3* | *1168.1* | *254.1* | *0.0* | *150.2* | 0.0 |
| សរុប | 292.0 | 1096.9 | 3802.4 | 2587.2 | 253.4 | 4176.5 | 4560.7 | 1580.3 | 928.6 | 39.4 | 386.3 | 4255.7 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | -78.1 | 1548.2 | 9.2 | -65.3 | -41.2 | -95.7 | 882.0 | 1001.7 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -5.6 | 275.6 | 246.6 | -32.0 | -49.1 | 2083.2 | 294.2 | 113.1 | 266.5 | -99.0 | -91.5 | 169.3 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៤-០៩

| | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 30.3 | 45.5 | 33.1 | 79.1 | 45.3 | 17.6 | 52.1 | 39.7 | 32.1 | 6.7 | 2.2 | 9.8 |
| ផ្ទះល្វែង | 167.6 | 204.2 | 213.3 | 297.2 | 40.9 | 55.1 | 65.6 | 60.0 | 95.2 | 18.9 | 6.3 | 28.0 |
| ផ្សេងៗ | 65.6 | 109.1 | 76.8 | 259.6 | 51.2 | 68.2 | 369.3 | 252.2 | 53.7 | 36.7 | 12.2 | 29.0 |
| សរុប | 263.5 | 358.8 | 323.3 | 635.8 | 137.3 | 140.9 | 486.9 | 351.9 | 181.1 | 62.3 | 20.7 | 66.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | -1.4 | 2.6 | 245.6 | -27.7 | -48.5 | -65.6 | -66.8 | 222.7 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 32.5 | 36.2 | -9.9 | 96.7 | -1.4 | -2.6 | 170.9 | 104.4 | 31.9 | -55.8 | -95.7 | -81.0 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

តារាង៣. ចំនួនអ្នកដំណើរមកដល់លើប្រទេសកម្ពុជា ឆ្នាំ២០០៤-០៩

| | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 626.1 | 856.5 | 1029.0 | 1296.5 | 402.0 | 262.0 | 259.2 | 316.2 | 335.2 | 221.2 | 247.2 | 308.1 |
| តាមផ្លូវគោក និងទឹក | 428.9 | 565.1 | 672.9 | 718.6 | 242.2 | 192.0 | 186.3 | 261.4 | 287.1 | 243.0 | 240.2 | 279.5 |
| សរុប | 1055.0 | 1421.6 | 1701.9 | 2015.1 | 644.2 | 454.0 | 445.5 | 577.6 | 622.3 | 464.2 | 487.4 | 587.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | 6.0 | -29.5 | -1.9 | 29.6 | 7.7 | -25.4 | 5.0 | 20.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 50.5 | 34.7 | 19.7 | 18.4 | 17.0 | 6.9 | 3.2 | -5.0 | -3.4 | 2.2 | 9.4 | 1.7 |

*Source: Ministry of Tourism*

តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៤-០៩

| | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 2108.1 | 2352.8 | 2799.9 | 3097.0 | 803.1 | 539.6 | 928.7 | 728.6 | 721.4 | 433.5 | 245.3 | 675.3 |
| ក្នុងនេះ: សំលៀកបំពាក់ | 2027.0 | 2253.3 | 2698.9 | 2938.9 | 773.4 | 463.8 | 868.8 | 678.8 | 606.9 | 377.3 | 240.0 | 652.9 |
| កៅស៊ូ | 38.3 | 36.7 | 41.4 | 41.6 | 7.0 | 11.0 | 12.9 | 5.2 | 11.8 | 8.2 | 4.9 | 16.2 |
| ឈើ | 11.1 | 10.3 | 8.6 | 4.1 | 0.0 | 0.0 | 0.0 | 0.0 | 0.1 | 0.1 | 0 | 1.2 |
| ត្រី | 10.6 | 10.1 | 5.9 | 3.2 | 0.7 | 0.3 | 0.6 | 0.6 | 0.9 | 0.7 | 0.4 | 5.0 |
| ការនាំចូលសរុប | 2149.0 | 2513.0 | 3057.0 | 3609.7 | 983.8 | 1178.5 | 1027.1 | 916.3 | 987.7 | 1060.8 | 366.5 | 1396.5 |
| ក្នុងនេះ: ផលិតផលប្រេងកាត | 187.0 | 184.8 | 238.5 | 264.9 | 60.0 | 64.6 | 68.3 | 62.9 | 67.3 | 72.2 | 89.0 | 341.6 |
| សំភារ:សំណង់ | 95.3 | 134.7 | 154.4 | 143.1 | 39.7 | 40.7 | 35.6 | 29.9 | 41.4 | 30.9 | 9.9 | 37.1 |
| ផ្សេងៗ | 1914.0 | 2245.0 | 2731.0 | 3216.6 | 884.1 | 1073.2 | 923.2 | 823.5 | 879.0 | 957.7 | 237.5 | 1017.8 |
| ជញ្ជីងពាណិជ្ជកម្ម | -40.9 | -160.1 | -257.1 | -511.2 | -180.7 | -638.9 | -98.4 | -187.7 | -157.6 | -627.3 | -91.2 | -721.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | 6.4 | -40.0 | 87.3 | -21.9 | -10.5 | -37.8 | -36.3 | 172.0 |
| ការនាំចេញសរុប | - | - | - | - | 1.2 | -32.8 | 72.1 | -21.5 | -0.9 | -39.9 | -43.4 | 175.3 |
| ការនាំចូលសរុប | - | - | - | - | 0.1 | 19.8 | -12.8 | -10.8 | 7.8 | 7.4 | -68.3 | 281.0 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | -64.9 | 291.4 | 19.8 | 8.9 | 14.2 | -32.6 | 2.7 | -6.6 | -21.5 | -18.6 | -72.4 | -3.8 |
| ការនាំចេញសរុប | 23.4 | 11.6 | 19.0 | 10.6 | 13.5 | -23.5 | 4.3 | -8.2 | -10.2 | -19.7 | -73.6 | -7.3 |
| ការនាំចូលសរុប | 17.8 | 16.9 | 21.6 | 18.1 | 24.4 | 29.3 | 11.1 | -6.8 | 0.4 | -9.9 | -67.2 | 52.4 |

*Import data include tax-exempt imports. Source:  Customs and Excise Department, cited by National Bank of Cambodia*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០៤-០៩ (ពាន់លានរៀល)

| | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2126 | 2625 | 3259.2 | 1146.1 | 1194.1 | 1463.6 | 1297.0 | 1335.3 | 1101.7 | 1252.7 | 1184.7 | 1346.1 |
| ចំណូលចរន្ត | 2107 | 2474 | 2881.8 | 1141.6 | 1189.4 | 1447.0 | 1288.3 | 1286.0 | 1097.7 | 1245.7 | 1174.9 | 1337.7 |
| ចំណូលពន្ធ | 1577 | 1911 | 2270.9 | 965.2 | 978.0 | 1255.0 | 1071.2 | 1105.7 | 947.4 | 1096.5 | 999.5 | 1224.1 |
| ពន្ធក្នុងស្រុក | - | - | - | 661.8 | 719.9 | 955.5 | 776.7 | 796.3 | 712.0 | 838.7 | 731.8 | 808.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | 303.5 | 258.1 | 299.5 | 294.5 | 309.4 | 235.4 | 257.8 | 268.0 | 303.4 |
| ចំណូលមិនមែនពន្ធ | 530 | 563 | 610.9 | 176.4 | 211.4 | 192.1 | 217.1 | 180.2 | 150.3 | 149.2 | 176.1 | 225.7 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | 13.6 | 2.9 | 53.9 | 11.0 | 10.2 | 13.1 | 9.7 | 27.5 | 14.3 |
| លក់ទំនិញ និងសេវា | - | - | - | 124.3 | 118.9 | 96.3 | 99.7 | 109.8 | 93.5 | 100.9 | 91.7 | 121.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | 38.5 | 89.6 | 41.9 | 106.4 | 60.3 | 43.7 | 38.6 | 56.5 | 89.5 |
| ចំណូលជាមូលធន | 19 | 152 | 377.4 | 4.5 | 4.8 | 16.5 | 8.7 | 49.3 | 4.0 | 7.0 | 9.8 | 8.4 |
| ចំណាយសរុប | 2932 | 3295 | 4174.7 | 1689.7 | 1059.1 | 1744.7 | 1662.8 | 1831.2 | 1650.6 | 1766.1 | 2089.5 | 1877.1 |
| ចំណាយជាមូលធន | 1163 | 1328 | 1638.1 | 807.4 | 411.0 | 648.2 | 641.2 | 874.0 | 693.6 | 607.1 | 759.2 | 634.9 |
| ចំណាយចរន្ត | 1769 | 1967 | 2536.8 | 882.3 | 648.1 | 1096.5 | 918.0 | 1146.4 | 752.4 | 1064.7 | 1290.4 | 1332.3 |
| បៀវត្សរ៍ | 640 | 711 | 822.0 | 362.6 | 250.7 | 367.0 | 363.6 | 415.7 | 327.4 | 515.5 | 526.6 | 642.5 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | 194.2 | 104.3 | 325.7 | 111.9 | 385.2 | 217.3 | 185.9 | 272.6 | 195.6 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | 325.5 | 193.1 | 403.8 | 442.6 | 345.4 | 207.7 | 363.2 | 491.2 | 494.3 |
| សមតុល្យជាទូទៅ | -806 | -706 | -915.6 | -543.6 | 135.0 | -281.1 | -365.8 | -495.9 | -548.9 | -513.4 | -904.8 | -531.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 864 | 1127 | 1360.7 | 741.5 | 299.2 | 615.8 | 435.0 | 705.1 | 507.8 | 326.7 | 484.5 | 406.4 |
| ហិរញ្ញប្បទានក្នុងស្រុក | 148 | -396 | -445.1 | -185.8 | -294.1 | -236.5 | 234.7 | 168.9 | -310.3 | 236.5 | 316.4 | 253.3 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៤-០៩

| | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | - | - | - | 5.8 | 20.6 | 33.3 | 28.7 | 17.8 | 4.3 | -4.8 | -3.0 | 1.7 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | 9.9 | 29.5 | 47.6 | 37.4 | 24.1 | 6.1 | -5.2 | -2.7 | 1.8 |
| - ដឹកជញ្ជូន | - | - | - | 5.8 | 21.7 | 28.9 | 27.8 | 4.1 | -13.0 | -16.5 | -13.8 | 2.4 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4016.3 | 4119.7 | 4119.0 | 4062.7 | 3995.3 | 4030.2 | 4117.5 | 4089.8 | 4111.6 | 4128.6 | 4164.4 | 4157.3 |
| រៀលក្នុង ១ បាតថៃ | 99.9 | 102.6 | 108.7 | 122.75 | 129.1 | 125.4 | 121.9 | 117.7 | 116.6 | 119.2 | 122.9 | 126.0 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.5 | 25.8 | 25.1 | 24.95 | 25.2 | 24.9 | 24.8 | 24.3 | 23.6 | 23.3 | 23.5 | 23.0 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 54.0 | 70.6 | 83.175 | 111.6 | 107.7 | 106.0 | 98.2 | 105.6 | 110.7 | 123.2 | 133.8 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2088 | 2633 | 3140 | 3262.25 | 3982 | 4975 | 5495 | 3768.9 | 2873.7 | 3056.9 | 3867.0 | 3381.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 2833 | 3442 | 4004 | 4005 | 4580 | 5171 | 5391 | 3861.3 | 3112.6 | 3452.4 | 3371.1 | 3940.2 |

*Sources: NIS, NBC and CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៤-០៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4797 | 5475 | 7224 | 37,607 | 10,911 | 11,353 | 10,809 | 10,345 | 11,222 | 12,611 | 13,869 | 14,655 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -467 | -450 | -282 | 281 | 1136 | 1345 | 1748 | 1513.3 | 1266 | 1249 | 1042 | 1573 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -209 | -421 | -953 | -5942 | -2400 | -2678 | -2653 | -2987 | -3048 | -2889 | -2463 | -2252 |
| ឥណទានដល់ផ្នែកឯកជន | 1817 | 2394 | 3630 | 20,365 | 8050 | 9206 | 9781 | 9894 | 9814 | 10,129 | 10,127 | 10,532 |
| រូបិយវត្ថុទូទៅ M2 | 4330 | 5025 | 6942 | 37,888 | 12,047 | 12,698 | 12,557 | 11,858 | 12,488 | 13,859 | 14,912 | 16,228 |
| រូបិយវត្ថុ M1 | 1153 | 1323 | 1658 | 7344 | 2389 | 2467 | 2335 | 2399 | 2545 | 2695 | 2773 | 3120 |
| រូបិយវត្ថុផ្សេងៗ | 3177 | 3702 | 5285 | 30,544 | 9658 | 10,231 | 10,223 | 9459 | 9942 | 11,164 | 12,139 | 13,108 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 30.0 | 16.1 | 38.1 | 445.8 | 54.5 | 43.1 | 26.7 | 4.8 | 3.7 | 9.1 | 18.7 | 36.9 |
| រូបិយវត្ថុ M1 | 23.0 | 14.7 | 25.3 | 342.9 | 33.2 | 41.1 | 33.4 | 16.9 | 6.5 | 9.2 | 18.7 | 30.1 |
| រូបិយវត្ថុផ្សេងៗ | 32.8 | 16.6 | 42.8 | 477.9 | 61.0 | 43.5 | 25.3 | 2.2 | 2.9 | 9.1 | 18.7 | 38.6 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលជាភាគរយ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2006 | 2007 | 2007 | 2008 | 2009 | | | | 2010 | ២០០៩ | | ២០១០ |
| | | | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា** | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 7469 | 8075 | 9675 | 12,628 | 8534 | 8896 | 7738 | 7446 | 9443 | -13.0 | -41.0 | 10.6 |
| អ្នកលីសែង | 6545 | 8588 | 9119 | 9005 | 10,476 | 10,319 | 8,159 | 9,566 | 9,984 | -20.9 | 6.2 | -4.7 |
| អ្នកលក់បន្លែតូចតាច | 6390 | 8220 | 8552 | 9926 | 7614 | 9764 | 8323 | 7647 | 7850 | -14.8 | -23.0 | 3.1 |
| អ្នករើសអេតចាយ | 4416 | 5422 | 5727 | 4652 | 5170 | 6637 | 7087 | 4693 | 6258 | 6.8 | 0.9 | 21.0 |
| អ្នកបំរើភោជនីយដ្ឋាន * | 4412 | 4482 | 4643 | 4327 | 4283 | 4346 | 4574 | 5568 | 5147 | 5.3 | 28.7 | 20.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5306 | 5516 | 6426 | 8697 | 7044 | 7126 | 5785 | 5003 | 5374 | -18.8 | -42.5 | -23.7 |
| កម្មកររោងចក្រកាត់ដេរ | 7649 | 7568 | 7240 | 6554 | 6754 | 6691 | 7410 | 7745 | 7581 | 10.8 | 18.2 | 12.2 |
| អ្នករត់ម៉ូតូឌុប | 8201 | 10,634 | 11,872 | 15,691 | 11,655 | 12,148 | 9569 | 9696 | 11,338 | -21.2 | -38.2 | -2.7 |
| កម្មករសំណង់គ្មានជំនាញ | 5918 | 6155 | 7777 | 8779 | 6115 | 9956 | 9444 | 8132 | 7723 | -5.1 | -7.4 | 26.3 |
| កម្មករសំណង់មានជំនាញ | 10,316 | 11,154 | 11,286 | 12,710 | 11,771 | 13,688 | 11,918 | 13,011 | 11,964 | -12.9 | 2.4 | 1.6 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*** Percentage change from the previous survey in August 2009 to May 2009*

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

នៅមុនពេលធ្វើសិក្ខាសាលាលើកចុងក្រោយ អំពីគម្រោងស្រាវជ្រាវនៃបណ្ដាញវិភាគអភិវឌ្ឍន៍ (DAN 8) នៅទីក្រុងហាណូយ ដែលមានវិទ្យាស្ថានកណ្ដាលសំរាប់ការគ្រប់គ្រងសេដ្ឋកិច្ច (CIEM) នៃប្រទេសវៀតណាម ធ្វើជាម្ចាស់ផ្ទះអ្នករៀបចំ ពួកស្ថាប័នជាសមាជិក DAN និងដៃគូផ្ដល់ធនធានជាសក្ដានុពលនានា បានដកឃ្លាទៅសំរាក ចំនួនមួយថ្ងៃ ដើម្បីពិភាក្សាពីសេចក្ដីព្រាងយុទ្ធសាស្ត្រមួយ សំរាប់បណ្ដាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) ឆ្នាំ២០១១-២០១៥ ដែលត្រូវកសាងជាបន្តបន្ទាប់ ឲ្យក្លាយជាបណ្ដាញស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍ឈានមុខ នៅមហាអនុតំបន់មេគង្គ ។

## ផ្នែកស្រាវជ្រាវ

ការស្រាវជ្រាវ និងសកម្មភាពពាក់ព័ន្ធដូចខាងក្រោមនេះ បានកើតមានឡើងក្នុងអំឡុងខែមេសា-មិថុនា ២០១០ ។

*កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ (DGPSR) ៖*

កម្មវិធីនេះកំពុងអនុវត្តគំរោងចំនួន ៧ ។ គំរោងទី១ "អភិបាលកិច្ចនៅមូលដ្ឋានលើធនធានទ្រព្យរួម៖ ករណីទឹកស្រោចស្រពនៅកម្ពុជា" ស្ថិតក្នុងដំណាក់កាលកែសម្រួលបង្ហើយ និងគ្រោងបោះពុម្ពផ្សាយនាពេលឆាប់ៗក្នុងឆ្នាំនេះ ។ គំរោងទី២ "ការវិភាគពីរដ្ឋកម្ពុជា៖ តើកម្ពុជាជារដ្ឋអភិវឌ្ឍន៍?" ក្រុមស្រាវជ្រាវបានបញ្ចប់ការចុះប្រមូលព័ត៌មានពីក្នុង ៤ខេត្ត ហើយបច្ចុប្បន្នកំពុងធ្វើប្លង់របាយការណ៍ ។ សំរាប់គំរោងទី៣ "ការវាយតម្លៃបែបគុណភាព ពីផលប៉ះពាល់នៃគំរោងសេវាច្រកចេញចូលតែមួយ" ដែលទទួលហិរញ្ញប្បទានពីធនាគារពិភពលោកនោះ គឺបានបញ្ចប់ដោយជោគជ័យ ហើយរបាយការណ៍ស្រាវជ្រាវ ក៏បានកែសំរួលជាឯកសារពិភាក្សាមួយដោយបានចេញជាឯកសារព្រាងទីមួយ នៅចុងខែមិថុនានេះ ។ គំរោងមួយទៀត "យេនឌ័រ និងអភិបាលកិច្ចមូលដ្ឋាន" ដែលទទួលមូលនិធិពីមជ្ឈមណ្ឌលអន្តរជាតិស៊ុយអែត ដើម្បីរបបប្រជាធិបតេយ្យនៅមូលដ្ឋាន បានចាប់ដំណើរការ ដោយក្រុមស្រាវជ្រាវកំពុងសិក្សាពីឯកសារយោង និងចុះសិក្សាដល់កន្លែង ។ ការចុះដល់កន្លែងលើកទីមួយ នៅខេត្តក្រចេះបានចប់សព្វគ្រប់ ហើយនឹងមានការចុះទៅខេត្តផ្សេងៗទៀត ។ គំរោងទី៥ "ការធ្វើបច្ចុប្បន្នភាពលើផែនការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម" ក្រោមជំនួយហិរញ្ញវត្ថុពីធនាគារពិភពលោក ផ្ដល់តាមរយៈក្រសួងពាណិជ្ជកម្ម (MOC) ជិតបានចប់សព្វគ្រប់ហើយ ដោយបានបញ្ចប់របាយការណ៍ព្រាងចុងក្រោយ និងផ្ញើជូនទៅ MOC នៅពាក់កណ្ដាលខែឧសភា ។ បច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងកែសម្រួលតាមមតិខ្លះៗ ទទួលបានពី MOC ហើយគ្រោងបង្ហើយរបាយការណ៍នៅដើមខែកក្កដា ២០១០ ។ ការសិក្សាពី "អភិបាលកិច្ចទឹក" កំពុងស្ថិតក្នុងដំណាក់កាលពិនិត្យឯកសារយោង និងសរសេររបាយការណ៍ ។ ក្រុមស្រាវជ្រាវ បានផ្ញើលិខិតមួយច្បាប់ទៅក្រសួងធនធានទឹក និងឧតុនិយម ដើម្បីស្នើសុំឯកសារខាងគោលនយោបាយ និងក្របខណ្ឌច្បាប់ និងស្នើសុំជួបសម្ភាសជាដំបូងៗ ។ គំរោងទី៧ "ការសិក្សាវិភាគពីវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា៖ ភាពផ្ទុយគ្នាស្រឡះរវាងមជ្ឈការ និងវិមជ្ឈការ" កំពុងបញ្ចប់ការកំណត់ក្របខ័ណ្ឌវិភាគ និងបន្តការងារពិនិត្យឯកសារយោង ។

*កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD) ៖*

មានគំរោងស្រាវជ្រាវចំនួន ៦ កំពុងអនុវត្តក្នុងកម្មវិធីនេះ ។ ការវិភាគជាដំបូងៗសំរាប់ "ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ" បានបញ្ចប់ ហើយការសរសេររបាយការណ៍បច្ចេកទេសកំពុងលូតលាស់ទៅមុខ ។ ក្រុមស្រាវជ្រាវ ក៏បានបញ្ជូនរបាយការណ៍ចុងក្រោយ ស្ដីពី "ការវាយតម្លៃលឿនពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច ទៅលើគ្រួសារនៅកម្ពុជា" ទៅឲ្យធនាគារពិភពលោក ដែលបានទទួលយក និងបានផ្ដល់ព័ត៌មានត្រលប់យ៉ាងល្អ ។ សំរាប់គំរោង "ការកសាងភាពធន់ទ្រាំ នៃសហគមន៍នេសាទនៅបឹងទន្លេសាប៖ សកម្មភាពរួមគ្នា និងសមត្ថភាពគ្រប់គ្រងធនធាន" ដែលទទួលហិរញ្ញប្បទានពីអង្គការ WorldFish ក្រុមស្រាវជ្រាវបានដំណើរការសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិមួយ និងបានផ្ញើរបាយការណ៍សំយោគ និងឯកសារសង្ខេបគោលនយោបាយទៅឲ្យ WorldFish ដើម្បីសុំមតិយោបល់ ។ របាយការណ៍ព្រាងទីមួយនៃគំរោង "ការវាយតម្លៃផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ចនៃច្រករបៀង នៅតំបន់ឆ្នេរភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ (GMS-SCC) និងការប្រយុទ្ធប្រឆាំងជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ (GMS-CDC)" កំពុងចងក្រងជិតបានរួចរាល់ សំរាប់បញ្ជូនទៅសុំមតិយោបល់ ។ គំរោង "ការធ្វើបច្ចុប្បន្នភាព លើផែនការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម" និង "ការវិភាគពីរដ្ឋកម្ពុជា៖ តើកម្ពុជាជារដ្ឋអភិវឌ្ឍន៍?" ជាគំរោងធ្វើរួមគ្នា ដោយកម្មវិធី ៣ ប្រចាំ CDRI គឺកម្មវិធី DGPSR កម្មវិធីសេដ្ឋកិច្ចពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC) និងកម្មវិធី PARD ។

*កម្មវិធីអភិវឌ្ឍន៍សង្គម (SD) ៖*

កម្មវិធីនេះបានអនុវត្តគំរោងចំនួន ៤ ។ សន្និសីទអន្តរជាតិ ស្ដីពី "ការលើកកំពស់លទ្ធផលក្នុងវិស័យសុខាភិបាល" បានរៀបចំឡើងនៅថ្ងៃទី ២៦-២៧ មេសា ២០១០ ក្នុងគោលដៅចំបង ចែករំលែកលទ្ធផលស្រាវជ្រាវ និងមេរៀននានា ស្ដីពីស្ថាប័ន សន្ទុះចិត្ត និងគ្រឿងលើកទឹកចិត្ត ដែលជួយសម្រួលដល់តរិយាបថរបស់អ្នកទទួល និងអ្នកផ្ដល់សេវាថែទាំសុខភាព ទាំងនៅកម្ពុជា ប្រទេសអាស៊ីឯទៀតៗ និងប្រទេសក្រៅពីនោះ ។ គំរោង "ការសិក្សាមូលដ្ឋានពីអ្នកគ្រប់គ្រងគន្លឹះ សំរាប់កម្មវិធីទ្រទ្រង់វិស័យសុខាភិបាល" និង "គ្រឿងលើកទឹកចិត្ត និងការរក្សាបុគ្គលិកសុខាភិបាលនៅតំបន់ជនបទ និងតំបន់អន់ថយនៃប្រទេសកម្ពុជា" បានចប់សព្វគ្រប់

ហើយរបាយការណ៍របស់គំរោង ក៏បានទទួលការយល់ស្របពីនាយកដ្ឋានសំរាប់ការអភិវឌ្ឍអន្តរជាតិ (DFID) ។ លទ្ធផលស្រាវជ្រាវសំខាន់ៗនៃគំរោងទាំងពីរនេះ បានលើកមកបង្ហាញក្នុងសិក្ខាសាលាស្រាវជ្រាវរបស់ CDRI និងសន្និសីទអន្តរជាតិស្ដីពីការលើកកំពស់លទ្ធផលក្នុងវិស័យសុខាភិបាល ។ គំរោង "ការវិភាគសុវត្ថិភាព សំរាប់សហគមន៍ក្រីក្រនៅក្រុងភ្នំពេញ" បានចប់ស្រេចបាច់ ហើយរបាយការណ៍គំរោង អង្គការ UN Habitat ក៏បានទទួលយកហើយដែរ ។

ក្រុមបណ្ដុះបណ្ដាលខាងកសាងសន្តិភាព បានធ្វើការបណ្ដុះបណ្ដាលចំនួន ៦ ម៉ូឌុល ក្នុងត្រីមាសនេះ ។ ក្រុមនេះ ក៏បានពិចារណាពីមេរៀនថ្មីៗទទួលបានពីការបណ្ដុះបណ្ដាល ផ្អែកលើករណីសិក្សាពីជំលោះលើបញ្ហាទឹក ដែលបានអនុវត្តសាកល្បងនៅខេត្តកំពង់ចាម វិធីសាស្ដ្រថ្មីមួយ សម្រាប់ការបណ្ដុះបណ្ដាលជាក់លាក់ពីទំនាស់ខាងនេសាទ និងដីធ្លីនៅខេត្តបាត់ដំបង និងការបណ្ដុះបណ្ដាលរួមគ្នាមួយ ជាមួយក្រសួងបរិស្ថាន សំរាប់មន្ត្រីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ មកពីតំបន់ជុំវិញបឹងទន្លេសាប ។ បច្ចុប្បន្នក្រុមបណ្ដុះបណ្ដាល កំពុងគ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយ ជាមួយស្ថាប័នបណ្ដុះបណ្ដាលខាងកសាងសន្តិភាពដទៃទៀត ។ នៅខែមិថុនា ២០១០ CDRI បានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងមួយ ជាមួយវិទ្យាស្ថានគោលនយោបាយសុខាភិបាលនៃប្រទេសស្រីលង្កា ដើម្បីចូលជាដៃគូសហការនៃបណ្ដាញរបាយការណ៍សុខភាពជាតិនៅអាស៊ី-ប៉ាស៊ីហ្វិក (Asia-Pacific National Health Accounts Network) ។ តាមរយៈបណ្ដាញសមធម៌ក្នុងប្រព័ន្ធសុខាភិបាលអាស៊ី-ប៉ាស៊ីហ្វិក (Equitap) កម្មវិធីអភិវឌ្ឍន៍សង្គម កំពុងអនុវត្តគំរោងមួយទទួលមូលនិធិពី AusAID គឺ "ការវិភាគទិន្នន័យអង្កេតគ្រួសារ ដើម្បីប៉ាន់ស្មានពី ផលប៉ះពាល់ដែលធ្វើឲ្យចុះក្រ និងជួបមហន្តរាយ ការរីកចំរើន និងភាពខុសគ្នាក្នុងការប្រើប្រាស់សេវាថៃទាំសុខភាព និងអត្ថប្រយោជន៍នៃចំណាយរបស់រដ្ឋាភិបាល" ។

*កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE) ៖*

កម្មវិធីនេះ បានអនុវត្តគំរោងស្រាវជ្រាវចំនួន ៦ ។ គំរោង "កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក" ចែកជាសមាសភាគ អភិបាលកិច្ច រូបវ័ន្ត និងសេដ្ឋកិច្ច ។ នៅពេលនេះក្រុមស្រាវជ្រាវកំពុងបង្ហើយរបាយការណ៍ដូចតទៅ៖ (១) ឯកសារពិភាក្សាពីការវាយតម្លៃខាងសង្គម មានចំណងជើងថា "ការវិភាគតាមការពិនិត្យឃើញជាក់ស្ដែង លើការគ្រប់គ្រងទឹកស្រោចស្រពនៅតំបន់អាងទន្លេសាប៖ ឧបសគ្គ និងបញ្ហាប្រឈម" (២) ឯកសារពិភាក្សាស្ដីពីសមាសភាគរូបវ័ន្ត "ការប្រើប្រាស់ចំណេះដឹងខាងធារាសាស្ដ្រ និងការចូលរួមរបស់សហគមន៍ ដើម្បីកែលំអការធ្វើសេចក្ដីសម្រេចចិត្តលើការបែងចែកទឹកស្រោចស្រព" (៣) សេចក្ដីព្រាងនៃឯកសារពិភាក្សាខាងសមាសភាគរូបវ័ន្ត "ការវិភាគពីផលប៉ះពាល់នៃការផ្លាស់ប្ដូរគំរបដី" (៤) សេចក្ដីព្រាងឯកសារពិភាក្សាខាងសមាសភាគអភិបាលកិច្ច "ការវិភាគច្រើនមុខពីអ្នកពាក់ព័ន្ធ" និង (៥) សេចក្ដីព្រាងនៃឯកសារពិភាក្សាខាងសមាសភាគសេដ្ឋកិច្ច "តម្លៃទឹកប្រើប្រាស់លើការដាំដុះ" ។ សម្រាប់គំរោង "ព្រៃតំបន់ត្រូពិច សំរាប់ការកាត់បន្ថយភាពក្រីក្រ-ការវិភាគទិន្នន័យតាំងពីកំរិតគ្រួសារដល់កំរិតសាកល" របាយការណ៍ជំនឿនការងារបានសរសេររួចរាល់ ហើយគ្រោងបញ្ជូនទៅឲ្យម្ចាស់ជំនួយនៅខែសីហា ២០១០ ។ សំរាប់គំរោង "ការកសាងសមត្ថភាពសហគមន៍សំរាប់ការផ្ដួចផ្ដើមគំនិតកាត់បន្ថយភាពក្រីក្រនៅតំបន់អាងទន្លេសាប" ក្រុមស្រាវជ្រាវកំពុងវិភាគលើលទ្ធផលទទួលបានពី ៥ សិក្ខាសាលាថ្នាក់ឃុំ ដែលបានធ្វើឡើងនៅជុំវិញបឹងទន្លេសាប ។ របាយការណ៍សំរេចនៃគំរោង "មាគ៌ាមានចីរភាព ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស" បានបញ្ជូនទៅ និងទទួលបានការយល់ស្របពីម្ចាស់ជំនួយ ។ ទាក់ទងនឹងគំរោង "ការកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទ នៅបឹងទន្លេសាប" ក្រុមស្រាវជ្រាវកំពុងចងក្រងឯកសារពិភាក្សាមួយ ស្ដីពី "ទំនាស់ និងសកម្មភាពរួមគ្នាក្នុងការនេសាទនៅបឹងទន្លេសាប" ។ គេរំពឹងថា គំរោងនេះនឹងចប់សព្វគ្រប់នៅខែកក្កដា ២០១០ ។ សំរាប់គំរោង "ការសិក្សាមូលដ្ឋានក្នុងកម្មវិធីស្ដីពីជីវភាពនេសាទតាមតំបន់ សំរាប់បណ្ដាខេត្តជាប់ឆ្នេរសមុទ្រនៅកម្ពុជា" អង្គការ FAO បានយល់ព្រមលើសំណើសុំអនុវត្តរួមគ្នាដោយកម្មវិធី PARD និង NRE ហើយបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងធ្វើសំណើពេញលេញមួយ សំរាប់គំរោងនេះ ។

*កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC) ៖*

កម្មវិធីនេះ បានអនុវត្តគំរោងស្រាវជ្រាវចំនួន ៨ ។ គំរោង "អង្កេតពលករងាយរងគ្រោះ" និង "អង្កេតថ្លៃទំនិញនៅតាមខេត្ត" កំពុងជឿនលឿនទៅមុខល្អ ។ សំរាប់សមាសភាគទីពីរ នៃ "គំរោងបណ្ដាញភាពក្រីក្ររបស់ ADB" ក្រុមស្រាវជ្រាវបានបញ្ចប់ក្របខ័ណ្ឌទស្សនទាននៃបញ្ហាបរិស្ថាន និងភាពក្រីក្រ ហើយរំពឹងថានឹងបង្ហើយរបាយការណ៍ព្រាងទីមួយ នៅខែសីហា ២០១០ ។ ការពិនិត្យសព្វគ្រប់ឡើងវិញពី បទបញ្ញត្តិ និងឯកសារយោងសំរាប់គំរោង "ចរន្តពលករខុសៗគ្នា គំរូការខុសៗគ្នា និងផលប៉ះពាល់ខុសៗគ្នា៖ ការគ្រប់គ្រងចំណាកស្រុក កំលាំងពលកម្មអន្តរជាតិនៅអាស៊ាន" បានចប់សព្វគ្រប់ របាយការណ៍បូកសរុបឡើងវិញ ក៏បានបញ្ជូនទៅឲ្យអ្នកសម្របសម្រួលគំរោង នៅឯវិទ្យាស្ថានហ្វីលីពីន សំរាប់ការសិក្សាពីអភិវឌ្ឍន៍ (PIDS) ហើយបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងរៀបចំការងារ សម្រាប់ការសុំជួបពិគ្រោះយោបល់ និងការចុះសិក្សាដល់កន្លែង ។ របាយការណ៍ព្រាងទីមួយនៃគំរោង "ការវាយតម្លៃពីឥទ្ធិពលសេដ្ឋកិច្ច-សង្គមកិច្ចនៃគំរោងរបស់មហាអនុតំបន់មេគង្គ (GSM)" បានបញ្ជូនទៅ ADB រួចហើយ ។ ក្រុមស្រាវជ្រាវបានធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវរបស់ខ្លួន ស្ដីពី "ការវាយតម្លៃពីផលប៉ះពាល់របស់ចិនលើការកាត់បន្ថយភាពក្រីក្រនៅ GSM (DAN 8)" នៅឯទីក្រុងហាណូយ កាលពីថ្ងៃទី ១០-១១ មិថុនា ២០១០ ។ គំរោង "ការវិភាគលើគំលាតពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា" និង "កម្ពុជា និងក្របខ័ណ្ឌ G20 សំរាប់កំណើនរឹងមាំមានចីរភាព

និងមានតុល្យភាព" ដែលទទួលមូលនិធិពី វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) បានចប់សព្វគ្រប់ និងទទួលបានការយល់ស្របពីម្ចាស់ជំនួយ ។ ក្រៅពីគំរោងស្រាវជ្រាវ ETRC ក៏បានចាប់អនុវត្តកម្មវិធីដោះដូរមួយ រវាងវិទ្យាស្ថានសិក្សាពីអាស៊ី-ប៉ាស៊ីហ្វិក នៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមចិន ហើយនិងវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។ សាស្ត្រាចារ្យ Guo Jiguang ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៃវិទ្យាស្ថានសិក្សាពីអាស៊ី-ប៉ាស៊ីហ្វិក មកធ្វើការនៅ CDRI ចាប់ពីចុងខែមិថុនា ២០១០ ចំនួន ៣ខែ ដើម្បីសិក្សាពី "វិនិយោគចិននៅកម្ពុជា" ។

ចាប់ពីឆ្នាំ២០០៧ មក CDRI បានធ្វើសិក្ខាសាលារៀងរាល់ពីរខែម្តង លើបញ្ហាអភិវឌ្ឍន៍ ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវ និងពង្រឹងគុណភាពស្រាវជ្រាវនេះ តាមរយៈការពិភាក្សា ការកែលំអវិធីសាស្ត្រស្រាវជ្រាវ ការបំផុសគោលគំនិត និងការវិភាគប្រធានបទស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសិក្ខាសាលា រួមមាន អ្នកស្រាវជ្រាវនៅ CDRI និង អ្នកស្រាវជ្រាវ និងអ្នកអនុវត្តផ្ទាល់ មកពីស្ថាប័នផ្សេងៗ និង NGOs នៅក្រុងភ្នំពេញ ។ អ្នកធ្វើបទបង្ហាញមកពី CDRI គឺមាន កញ្ញា អ៊ូច ច័ន្ទតារ៉ានី និង លោក សាំង ច័ន្ទហង្ស ជាអ្នកស្រាវជ្រាវនៃកម្មវិធី ETRC លោក គឹម សុធន អ្នកស្រាវជ្រាវនៃកម្មវិធី PARD និង វេជ្ជ. សេង ប៊ុនដេត និង លោក នេត នាថ នៃកម្មវិធី SD ។ ប្រធានបទមានដូចជា ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ច ពាណិជ្ជកម្ម ធនធាន ធម្មជាតិ និងកសិកម្ម ។

*តពីទំព័រ ១* ការសំរេចបានកំណើន...

ម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាព និងការគ្រប់គ្រងល្អ ដែលបើកឱកាសឲ្យ និងលើកកំពស់ពិពិធកម្មសេដ្ឋកិច្ច ភាពប្រកួតប្រជែង និងផលិតភាព ការពង្រឹងវិស័យសំខាន់ៗសំរាប់ការនាំចេញ ជាមួយនឹងការកៀងគរប្រាក់សន្សំ និងចំណាយប្រើប្រាស់ក្នុងស្រុក ការអភិវឌ្ឍធនធានមនុស្ស (ជាពិសេសតាមរយៈការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) និងការធ្វើសមាហរណកម្មជាយុទ្ធសាស្ត្រនៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគសំខាន់ៗរបស់ខ្លួន ជាមួយនឹងមហាអនុតំបន់មេគង្គ តំបន់អាស៊ាន តំបន់អាស៊ានធំទូលាយ ប្រទេសចិន កូរ៉េខាងត្បូង និងជប៉ុន និងជាមួយទីផ្សារអន្តរជាតិផ្សេងៗទៀត ។

កម្មវិធី បទបង្ហាញ និងឯកសារផ្សេងៗជាប់ទាក់ទងនឹងសន្និសីទចក្ខុវិស័យ២០១០ មានចុះនៅក្នុងវេបសាយរបស់ CDRI ។ វិទ្យាស្ថាន ក៏បានរៀបចំនូវកំរងអត្ថបទសង្ខេបចក្ខុវិស័យកម្ពុជា ដែលបង្ហាញពីបញ្ហាចំបងៗ ព្រមទាំងអនុសាសន៍ខាងគោលនយោបាយ និងសកម្មភាព សំរាប់ចែកជូនដល់ភ្ញៀវកិត្តិយសនៃសន្និសីទ និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងសហគមន៍អភិវឌ្ឍន៍កម្ពុជា ។ ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជាក្នុងលេខនេះ មានចុះផ្សាយអត្ថបទសំខាន់ៗ ផ្អែកលើបទបង្ហាញតាមវគ្គ និងប្រធានបទ នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០ ។

## Cambodia Development Review—2010 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........................................................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........................................................................

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒Other ..........................................................................

First name: .................................... Family name: .................................... Position: ....................................

Organisation / Company: ..........................................................................

Address (CCC Box if applicable): ..........................................................................

City / Province: .................................... Country: ....................................

Telephone: .................................... Fax: ....................................

e-mail: .................................... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

កាលពីថ្ងៃទី ២៣ មេសា ២០១០ តំណាង CDRI បានអញ្ជើញចូលរួមសិក្ខាសាលាកម្ពុជាឆ្នាំ២០១០ នៅសិង្ហបុរី ដែលសហការរៀបចំដោយវិទ្យាស្ថានសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ (ISEAS) និងវិទ្យាស្ថានកម្ពុជាដើម្បីកិច្ចសហប្រតិបត្តិការ និងសន្តិភាព (CICP) ។ លោក ឡារី ស្ទ្រេនន្ទ នាយកប្រតិបត្តិនៃ CDRI បានធ្វើជាប្រធានវគ្គស្តីពីធនធានមនុស្សសំរាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា ហើយវាគ្មិននៅក្នុងវគ្គនេះ រួមមានលោកជំទាវ បណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី លោក គឹម សេតារា អ្នកស្រាវជ្រាវជាន់ខ្ពស់ CDRI និងលោកសាស្ត្រាចារ្យ Kwok Kian Woon នៃសាកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង ប្រទេសសិង្ហបុរី ។

កម្មវិធីអភិវឌ្ឍន៍សង្គម ដែលទើបបង្កើតថ្មីរបស់វិទ្យាស្ថាន CDRI បានសម្រេចការងារខាងអភិវឌ្ឍន៍ដ៏សំខាន់មួយ ដោយបានសហការជាមួយវិទ្យាស្ថានគោលនយោបាយអ៊ិកស្វដ (OPI) ក្រោមជំនួយហិរញ្ញវត្ថុពី នាយកដ្ឋានសំរាប់ការអភិវឌ្ឍអន្តរជាតិអង់គ្លេស (UK-DFID) រៀបចំធ្វើសន្និសីទអន្តរជាតិខាងសុខាភិបាលមួយ ស្តីពីការលើកកំពស់លទ្ធផលក្នុងវិស័យសុខាភិបាល៖ ស្ថាប័ន សន្ទុះចិត្ត និង ការលើកទឹកចិត្ត ។

កាលពីខែឧសភា លោកនាយកប្រតិបត្តិ នៃ CDRI បានដកឃ្លាធ្វើដំណើរទៅធ្វើបទឧទ្ទេសនាម នៅមជ្ឈមណ្ឌលស្រាវជ្រាវពីទំនាក់ទំនងអន្តរជាតិ នៃវិទ្យាស្ថានវិទ្យាសាស្ត្រនយោបាយនៃប្រទេសបារាំង ។ ក្នុងអំឡុងពេលនោះ លោកបានធ្វើបទបង្ហាញពីឯកសារស្រាវជ្រាវមួយ និងបានចូលរួមក្នុងសិក្ខាសាលាអាស៊ី-អឺរ៉ុប ដោយធ្វើជាប្រធានវគ្គ ស្តីពីបទពិសោធន៍ធ្វើសមាហរណកម្មក្នុងតំបន់របស់ទ្វីបអាស៊ី និងអឺរ៉ុប ។ លោកក៏បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាមួយ មានរយៈពេល ២ថ្ងៃ ដោយបានធ្វើបទបង្ហាញអំពីនិន្នាការតំបន់និយមនៅអាស៊ី ឲ្យដល់ពួកនិស្សិតអន្តរជាតិមកពីកម្មវិធីវិទ្យាសាស្ត្រនយោបាយខាងអាស៊ី និងបានធ្វើការពិគ្រោះយោបល់ជាមួយពួកអ្នកស្រាវជ្រាវ អំពីបញ្ហាចោទ និងឱកាសល្អសំរាប់កិច្ចសហការស្រាវជ្រាវទៅអនាគតជាមួយ CDRI ។

ក្រោយពេលក្រុមប្រឹក្សាភិបាល នៃ CDRI បានអនុម័តយល់ព្រម លើឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រស្រាវជ្រាវនៅប្រទេសកម្ពុជាឆ្នាំ២០២០ ដែលជាមូលដ្ឋានសំរាប់ធ្វើផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ របស់ CDRI និងធ្វើជាយានដើម្បីទទួលបានជំនួយគាំទ្រហិរញ្ញវត្ថុរយៈពេលវែង និងការសំរបសំរួលកាន់តែល្អ នៅខែមិថុនា ២០១០ CDRI បានចាប់ផ្តើមដំណើរការពិគ្រោះយោបល់ជាមួយខាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍អ្នកស្រាវជ្រាវ ដើម្បីកសាងយុទ្ធសាស្ត្រឲ្យបានពេញលេញ សំរាប់ដាក់ស្នើសុំអនុមតិនៅពេលប្រជុំពេញអង្គលើកក្រោយនៃក្រុមប្រឹក្សាភិបាល CDRI នៅខែមីនា ២០១១ ។

នៅខែមិថុនា ២០១០ តំណាង វបសអ បានអញ្ជើញទៅក្រុងបាងកក ដើម្បីចូលរួមវេទិកាប្រចាំឆ្នាំនៃបណ្តាញអភិវឌ្ឍន៍អាស៊ីបូព៌ា ដែលមានជំនួយទ្រទ្រង់ពីធនាគារពិភពលោក និងមានវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ថៃ ធ្វើជាម្ចាស់ផ្ទះ ។ ក្នុងខែមិថុនានេះដែរ

*(តទៅទំព័រ ២១)*

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៤ លេខ២ ខែមេសា-មិថុនា ឆ្នាំ២០១០

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅ នៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@wicam.com.kh

website: http://www.cdri.org.kh

គ្រឹះស្ថានផ្សាយៈ វបសអ

គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ

កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា

ជំនួយការកែសំរួលៈ ខេង សេង និង អ៊ឹង សុជាតិ

រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

9 789995 052065

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។